# ពុទ្ធសាសនា និង សង្គម

រៀបរៀងដោយ
ភិក្ខុ ចិន ភេន ឥន្ទបញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន
លើកទី ១ ចំនួន ១៥០០ ក្បាល

# ពុទ្ធសាសនា និង សង្គម


រៀបរៀងដោយ

ភិក្ខុ ចិន គេន ឥន្ទបញ្ញោ

វាយកុំព្យូទ័រ និង ចាត់ការដោយ

ភិក្ខុ ពេជ្រ សាម៉ុន



បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស

ព.ស. ២៥៥៦ គ.ស. ២០១២

# អារម្ភកថា

ក្នុងឱកាសដែលខ្ញុំ មានអាយុគ្រប់ ៨៤ ឆ្នាំ ពេញបរិបូណ៌ នៅថ្ងៃ ៨ ខែតុលា ឆ្នាំ ២០១២ នេះ ខ្ញុំបានប្រមូលរៀបរៀង នូវពុទ្ធវចនៈមួយចំនួន ដែលជាប់ទាក់ទងនឹងជីវិតមនុស្សក្នុងសង្គម ទុកជាទីនឹករលឹក ។ ខ្ញុំ មានសេចក្ដីស្ដាយ ដោយខ្ញុំ មិនបាន ប្រមូលទុក នូវពុទ្ធវចនៈឲ្យបានច្រើនជាងនេះ ព្រោះខ្ញុំ មានកិច្ចការច្រើនពេក ។

ខ្ញុំ សង្ឃឹមថា កូនសៀវភៅដ៏តូចនេះ នឹងបានជាពន្លឺខ្លះ ដល់លោកអ្នកអាន ជាពុំខាន ៕

វត្តពោធិវង្ស, ថ្ងៃ ៨ ខែតុលា ឆ្នាំ ២០១២

**ភិក្ខុ ខិន គេន ឥន្ទប្បញ្ញោ**

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

## ពុទ្ធសាសនា និង សង្គម

១*៧

ពុទ្ធសាសនា ប្រែថា សាសនារបស់ព្រះពុទ្ធ ឬ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ សង្គម ប្រែថា ការរួម ឬ ការរួមរស់នៅជាមួយគ្នា របស់មនុស្ស ។ សង្គមគ្រួសារ សង្គមភូមិ ឃុំសង្គម ស្រុក ខេត្ត សង្គមប្រទេសជាតិ ។

### សង្គមសាស្ត្រ ក្បួននិយាយពីសង្គម

ក្នុងសង្គមសាស្ត្រ គេចែកសង្គមជា ៤ គឺ:

១-សង្គមដើម

២-សង្គមសក្តិភូមិ

៣-សង្គមមូលធននិយម

៤-សង្គមនិយម ។

ក្នុងសៀវភៅនេះ ខ្ញុំមិននិយាយពីសង្គមវិទ្យាទេ ខ្ញុំគ្រាន់តែចង់បង្ហាញឲ្យដឹងថា ព្រះពុទ្ធ ឬ ពុទ្ធសាសនា មាននិយាយអ្វីខ្លះដែរជាប់ទាក់ទងនឹងសង្គម តែប៉ុណ្ណោះ ។ ពុទ្ធសាសនា ល្អ ឬ មិនល្អមានប្រយោជន៏ ឬ មិនមានប្រយោជន៏ គិតពិចារណាខ្លួនឯងចុះ ។

### ការផ្សព្វផ្សាយពុទ្ធសាសនា

បន្ទាប់ពីបានត្រាស់ដឹង នូវសម្មាសម្ពោធិញ្ញាណ ព្រះពុទ្ធបានសម្តែងធម៏ប្រោសបញ្ចវគ្គីយ៏ ៥ រូប បន្ទាប់មកទៀត សម្តែង

ធម៌ប្រោសព្រះយស និង សម្លាញ់ ៥៤ រូប រួមទាំង ព្រះពុទ្ធផង ពេលនោះ ព្រះអរហន្ត មានចំនួន ៦១ អង្គហើយ ។ ព្រះពុទ្ធ បាន បញ្ជូនសាវកទាំងអស់នោះ រួមទាំងព្រះអង្គផង ឲ្យចេញទៅ ប្រកាសផ្សាយ ពុទ្ធសាសនា ដោយពុទ្ធដីកាថា **ចរថ ភិក្ខវេ ចារិកំ ពហុជនហិតាយ ពហុជនសុខាយ លោកានុ-កម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ...** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅកាន់ចារិក ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីគុណ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និង មនុស្សទាំងឡាយ...[១] ។

សេចក្តីខ្លីប៉ុណ្ណេះ បញ្ជាក់បានច្បាស់លាស់ហើយ នូវទឹកព្រះទ័យរបស់ព្រះពុទ្ធ និង ទិសដៅរបស់ពុទ្ធសាសនា ។

❋❋❋

## គួរជឿ គិត ពិចារណា

សម័យមុន ពួកកុម្មុយនិស្ត គេថា ព្រះសង្ឃយើងជាបញ្ញើក្អែក ជាឈ្លើង ជាព្រូន ជញ្ជក់ឈាមប្រជាជន ប៉ុន្តែ សម័យ

---

(១)- វិន័យបិដក មហាវគ្គ មហាខន្ធកៈ ៦-៣២-៦៦

បច្ចុប្បន្ន ពុទ្ធបរិស័ទ គេថា ព្រះសង្ឃយើង ស្រវឹង បុណ្យសក្តិ សម្ភារនិយម សន្សំប្រយោជន៍ផ្ទាល់ខ្លួន... តើពិត ឬ មិនពិត គិតមើលទៅ ។ ប្រទេសជាតិកំពុងលិចលង់ ប្រជាជន កំពុងរងទុក្ខធំ យំអស់ទឹកភ្នែកហើយ ប៉ុន្តែ ព្រះសង្ឃស្រវឹង មហាកុដិ រថយន្តថ្មីៗ.. សប្បាយហ៊ឺហា ថ្ងៃថ្នូរអស្ចារ្យ សំពះ បាសក ។ ស្រីម្នាក់គេថា អស្ចារ្យ ! ជិះដីរ៉ាបចផ្កា ដល់ស្រុកឥណ្ឌា សម្បូរហូរហៀរ មិនដឹងដីស្រុត ជាតិជិតរលត់ សាសនារលាយ សប្បាយអស្ចារ្យ! ។ ឱ ! បង្គួយបានកម្រងផ្កា ស្វាបានមកុដ បើខ្ញីកំប៉ុត ម៉េចក៏ថាវែង ។

# អត្ថៈ ប្រយោជន៍ ៣ យ៉ាង

១-ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ក្នុងបច្ចុប្បន្ន គឺបានទទួលផល ក្នុងជាតិនេះ ។

២-សម្បរាយិកត្ថៈ ប្រយោជន៍ក្នុងជាតិមុខ គឺបានទទួល ផល ក្នុងជាតិខាងមុខ ។

៣-បរមត្ថៈ ប្រយោជន៍ខ្ពស់បំផុត គឺ ព្រះនិព្វាន បាន ដល់ការរំលត់ភ្លើងទុក្ខ គឺបញ្ចក្ខន្ធ រំលត់ភ្លើងកិលេស គឺ រាគៈ ទោសៈ មោហៈ [២] ។

---

[២]-សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស ៦៨-២៤១-២១៧

កំណត់ចំណាំ : សាសនាឯទៀត បានត្រឹមប្រយោជន៍ ២ ទៅ មិនដល់ព្រះនិព្វានទេ ។ មានតែ ពុទ្ធសាសនា មួយប៉ុណ្ណោះ ដែលបានសម្រេចដល់ប្រយោជន៍ខ្ពស់បំផុត គឺ ព្រះនិព្វាន ៕

## ទីឃជាណុសូត្រ

៙✿៚

ទីឃជាណុកោឡិយបុត្រ ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាគ្រហស្ថ បរិភោគកាម ទ្រទ្រង់ផ្កាកម្រង គ្រឿងលាប គ្រឿងក្រអូប ត្រេកអរនឹងមាសប្រាក់ សូមព្រះអង្គ ទ្រង់ព្រះមេត្តា សំដែងធម៌ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន និង ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខ ដល់ខ្ញុំព្រះអង្គ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែង ដូចតទៅនេះ :

**ទិដ្ឋធម្មិកត្ថៈ** ប្រយោជន៍ក្នុងបច្ចុប្បន្ន

ប្រយោជន៍ក្នុងបច្ចុប្បន្ន ត្រូវប្រកបដោយធម៌៤ គឺ:

**១-ឧដ្ឋានសម្បទា** ដល់ព្រមដោយសេចក្តីប្រឹងប្រែង បដិបត្តិ នាទីការងារ ហ្វឹកហាត់ឲ្យស្ទាត់ជំនាញក្នុងមុខរបរផ្សេងៗ ស្របតាមកាលៈទេសៈ ។

២-**អារក្ខសម្បទា** ដល់ព្រមដោយការថែរក្សាទ្រព្យសម្បត្តិ និងលទ្ធផលនៃការងារដែលស្វែងរកបានមក មិនឲ្យបាត់បង់សាបសូន្យទៅ ។

៣-**កល្យាណមិត្តតា** សេពគប់រាប់រកយកមនុស្សល្អជាមិត្រ ដែលមានគុណសម្បត្តិជួយណែនាំ ឲ្យកាន់តែបានសុខ-ចំរើនឡើងថែមទៀត ។

៤-**សមជីវិតា** ចិញ្ចឹមជីវិតស្មើ សមរម្យល្អ មិនខ្វះខ្វាយ មិនត្បិតត្បៀត ចំណាយតិចជាងចំណូល ។

បើគេប្រកបដោយធម៌ ៤ នេះហើយ គេនឹងទៅជាអ្នកមានឬយ៉ាងហោចណាស់ ក៏គ្រប់គ្រាន់ មិនជំពាក់វាក់វិនបុគ្គលណាឡើយ ។ បន្ថែមពីលើនេះទៀត គេត្រូវវៀរអបាយមុខ ៤ យ៉ាងគឺៈ

១-**ឥត្ថីធុត្តោ** អ្នកលេងស្រី

២-**សុរាធុត្តោ** អ្នកលេងសុរា មេរ័យ គ្រឿងញៀន

៣-**អក្ខធុត្តោ** អ្នកលេងល្បែងភ្នាល់

៤-**បាបមិត្តោ** អ្នកយកមនុស្សអាក្រក់ជាមិត្រ ។

## **សម្បរាយិកត្ថៈ** ប្រយោជន៍ក្នុងជាតិមុខ

ប្រយោជន៍ក្នុងជាតិមុខ ត្រូវប្រកបដោយធម៌ ៤ គឺៈ

១-**សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា គឺ មានជំនឿប្រ-កបដោយបញ្ញា ។

២-**សីលសម្បទា** ដល់ព្រមដោយសីល គឺរក្សាកាយ វាចា រៀបរយ មានសីលធម៌ ។

៣-**ចាគសម្បទា** ដល់ព្រមដោយការលះបង់ គឺលះបង់ទ្រព្យជាដើម ដើម្បីសេចក្ដីសុខដល់អ្នកដទៃ ។

៤-**បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា គឺគិតពិចារណាម៉ត់ចត់ហើយ ទើបនិយាយ ទើបធ្វើ (៣) ។

បុគ្គលអ្នកប្រកបដោយធម៌ ៤ យ៉ាងនេះ លុះស្លាប់ទៅ រមែងបានទៅកើតជាមនុស្ស ឬ ទេវតា ដែលគេរាប់ថាជាផលប្រយោជន៍ក្នុងជាតិមុខ ។ ចំណែក អ្នកប្រកបដោយអកុសលធម៌ ស្លាប់ទៅ រមែងទៅកើតក្នុងអបាយភូមិ មាននរកជាដើម មិនរាប់ថាជាផលប្រយោជន៍ក្នុងជាតិខាងមុខទេ ។

## បរមត្ថៈ

ប្រយោជន៍ខ្ពស់បំផុត គឺ និព្វាន

## និព្វាន ២ យ៉ាង

១-**សឧបាទិសេសនិព្វាន** និព្វានមានឧបាទិ (បញ្ចក្ខន្ធ) សល់

---

(៣)-សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត ៤៨-៥៤-២៤៣

ឬហៅថា កិលេសនិព្វាន ។

២-**អនុបាទិសេសនិព្វាន** និព្វានមិនមានឧបាទិសល់ ។ ឬហៅថា ខន្ធនិព្វាន[៤] ។

**រាគក្ខយៈ** ការអស់ទៅនៃរាគៈ **ទោសក្ខយៈ** ការអស់ទៅនៃទោសៈ **មោហក្ខយៈ** ការអស់ទៅនៃមោហៈ **ឥទំ វុច្ចតិ និព្វានំ** នេះហៅថា និព្វាន ។ ពោលដោយខ្លី **តណ្ហក្ខយៈ** ការអស់ទៅនៃតណ្ហា ជាហេតុកើតឡើងនៃទុក្ខ ហៅថា និព្វាន ។

បុគ្គលអ្នកបានសម្រេចប្រយោជន៍ខ្ពស់បំផុត គឺ និព្វាន ត្រូវធ្វើដំណើរ គឺបដិបត្តិអរិយដ្ឋង្គិកមគ្គ ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរ :

១-**សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ

២-**សម្មាសង្កប្ប** សេចក្តីត្រិះរិះត្រូវ

៣-**សម្មាវាចា** ពាក្យសំដីត្រូវ

៤-**សម្មាកម្មន្ត** ការងារត្រូវ

៥-**សម្មាអាជីវ** ការចិញ្ចឹមជីវិតត្រូវ

៦-**សម្មាវាយាម** ការព្យាយាមត្រូវ

៧-**សម្មាសតិ** ការរលឹកត្រូវ

៨-**សម្មាសមាធិ** ការតាំងចិត្តមាំត្រូវ ។

---

[៤]-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ ៥៣-៤៤-៥០

## **អត្ថៈ** ប្រយោជន៍ ៣ យ៉ាងទៀត

១-**អត្តត្ថៈ** (អត្តទត្ថៈ) ប្រយោជន៍ខ្លួន

២-**បរត្ថៈ** ប្រយោជន៍អ្នកដទៃ

៣-**ឧភយត្ថៈ** ប្រយោជន៍ទាំងពីរ[៥] ។

ប្រយោជន៍ខ្លួន អន់ជាទីបំផុត ប្រយោជន៍ទាំងពីរ ប្រសើរជាទីបំផុត ។ ប្រយោជន៍អ្នកដទៃ គឺដទៃក្រៅពីខ្លួន ទោះបីក្នុងគ្រួសារក្តី ក្រៅគ្រួសារ ឬ មហាជនទូទៅក្តី ។ ពាក្យថាប្រយោជន៍រួម នៅក្នុងពាក្យថា **បរត្ថៈ** នេះ ។ ឯពាក្យថា **លោកត្ថៈ** ប្រយោជន៍សត្វលោក ខ្ពស់ជាងពាក្យថា **បរត្ថៈ** សំរាប់ប្រើជាមួយអ្នកកសាងជាពុទ្ធភូមិ ប៉ុណ្ណោះ ៕

## **អនណសូត្រ**

### សុខរបស់គ្រហស្ថ

អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី គិហិសុខ មាន៤ យ៉ាង គឺ :

១-**អត្ថិសុខ** សុខកើតអំពីការមានទ្រព្យ ។ ព្រោះមានទ្រព្យ

---

[៥]-សុត្តន្តបិដក ខុទ្ទកនិកាយ ចូឡនិទ្ទេស ៦៨-២៤១-២១៧

ទើបមានចំណីអាហារ សម្លៀកបំពាក់ ទីស្នាក់អាស្រ័យ និង ថ្នាំព្យាបាលរោគ ។ គ្រហស្ថ ដែលខំប្រឹងរកទ្រព្យសម្បត្តិ បើមានទ្រព្យច្រើន ឬ មានគ្រប់គ្រាន់ គេរមែងមានសេចក្ដីសុខ (មោទនភាព) ចំពោះការមានទ្រព្យសម្បត្តិនេះ ។

២-**ភោគសុខ** សុខកើតអំពីការបរិភោគ គឺចេះចាយវាយទ្រព្យ បើគេចេះទុកដាក់ ចេះចិញ្ចឹមខ្លួន ប្រពន្ធ កូន មាតាបិតា ...ឲ្យបានសុខ និង ចេះធ្វើបុណ្យទានតាមសមគួរ គេរមែងមានសេចក្ដីសុខ អំពីការចេះចាត់ចែងចាយវាយទ្រព្យនេះ ។

៣-**អនណសុខ** សុខកើតអំពីការមិនមានបំណុល ។ បំណុលជាបន្ទុកមួយធ្ងន់ណាស់ ។ គ្រហស្ថ បើគេចេះរកទ្រព្យចិញ្ចឹមខ្លួន... បាន ដោយមិនមានបំណុល ទុកជាការប្រសើរហើយ គួរឲ្យមានមោទនភាព ។ ប៉ុន្តែ បើមានបំណុល គេមិនត្រូវសប្បាយភ្លេចខ្លួន ត្រូវខំលៃលកសងបំណុលឲ្យអស់សិន សឹមសប្បាយ ។

៤-**អនវជ្ជសុខ** សុខកើតអំពីការងារមិនមានទោស ។ ការងារចិញ្ចឹមជីវិតស្របតាមច្បាប់ និង ត្រូវតាមគន្លងធម៌ក្ដី ការប្រព្រឹត្តរាល់ថ្ងៃ ប្រកបដោយកាយសុចរិត វចីសុចរិត មនោសុចរិតក្ដី នេះហៅថា ការងារមិនមានទោស ។ ការងារមិនមានទោសនេះ សំខាន់បំផុតហើយ គ្មានអ្វីប្រៀបផ្ទឹមបានទេ ។ បើគេ

ធ្វើបាន គេរមែងមានសេចក្ដីសុខ ទាំងក្នុងជាតិនេះ និង ជាតិខាងមុខ[៦] ។

គ្រហស្ថ បើគេប្រកបដោយគុណធម៌ ៤ ប្រការនេះហើយ ឈ្មោះថា គេមានសេចក្ដីសុខហើយ ។ ឯទុក្ខផ្សេងៗទៀត ជាការធម្មតារបស់មនុស្ស ។

## អាទិយសូត្រ

៣✻៧

អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតី ការកាន់យកប្រយោជន៍ពីភោគសម្បត្តិ (ភោគអាទិយៈ) មាន ៥ យ៉ាង គឺៈ

១-ចិញ្ចឹមខ្លួន មាតាបិតា បុត្រភរិយា ទាសកម្មករ ឲ្យបានសុខ ។

២-ទំនុកបំរុង មិត្រអាមាត្យ ឲ្យបានសុខ ។

៣-ការពារអន្តរាយ ដែលកើតពីភ្លើង ទឹក ព្រះរាជា ចោរ និង ពួកទាយាទមិនជាទីស្រឡាញ់ ដើម្បីធ្វើខ្លួនឲ្យមានសុវត្ថិភាព ។

៤-ធ្វើពលី ៥ យ៉ាង

(១)-**ញាតិពលី** សង្គ្រោះញាតិ

---

(៦)-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២-៦៣-១៧០

(២)-**អតិថិពលី** ទទួលភ្ញៀវ

(៣)-**បុព្វបេតពលី** ឧទ្ទិសកុសលដល់ពួកញាតិ ដែលស្លាប់ហើយ

(៤)-**រាជពលី** ជួយប្រទេសជាតិ

(៥)-**ទេវតាពលី** ឧទ្ទិសកុសលថ្វាយទេវតា ។

៥-ធ្វើទក្ខិណាទានដ៏ខ្ពង់ខ្ពស់ ចំពោះសមណព្រាហ្មណ៍ អ្នកប្រព្រឹត្តល្អ មិនប្រមាទ មានខន្តិសោរច្ចៈ អ្នកទូន្មានខ្លួន អ្នករំលត់កិលេស ជាបុណ្យមានសេចក្ដីសុខជាផល...[៧] ។

បើគេកាន់យកប្រយោជន៍អំពីភោគសម្បត្តិ ៥ យ៉ាងនេះបានហើយ សូម្បីទ្រព្យអស់ទៅ ក៏មិនជាការអ្វី ព្រោះគេបានធ្វើល្អហើយ បើទ្រព្យគេនៅតែចំរើនឡើងថែមទៀត ក៏រឹតតែប្រសើរ ។

## កាមភោគីសូត្រ

៣*៧

អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ត្រាស់ទៅកាន់អនាថបិណ្ឌិកគហបតីថា ម្នាលគហបតី កាមភោគីបុគ្គល ១០ ពួក មាននៅក្នុងលោក គឺៈ

១-ក្រុមទី ១ ស្វែងរកទ្រព្យមិនប្រកបដោយធម៌ បានទ្រព្យ

---

[៧]-សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត អាទិយសូត្រ ៤៤-៤១-៨៩

មកហើយ ប្រព្រឹត្តដូចនេះ –

១-មិនចិញ្ចឹមខ្លួនឲ្យបានសុខ មិនចាត់ចែងបែងធ្វើបុណ្យទាន ។

២-ចិញ្ចឹមខ្លួនឲ្យបានសុខ តែមិនចាត់ចែងបែងធ្វើបុណ្យទាន

៣-ចិញ្ចឹមខ្លួនឲ្យបានសុខផង ចាត់ចែងបែងធ្វើបុណ្យទានផង ។

ក្រុមទី ២- ស្វែងរកទ្រព្យប្រកបដោយធម៌ខ្លះ មិនប្រកបដោយធម៌ខ្លះ បានទ្រព្យមកហើយ ប្រព្រឹត្តដូចនេះ –

៤-មិនចិញ្ចឹមខ្លួនឲ្យបានសុខ មិនចាត់ចែងបែងធ្វើបុណ្យទាន ។

៥-ចិញ្ចឹមខ្លួនឲ្យបានសុខ តែមិនចាត់ចែងបែងធ្វើបុណ្យទាន

៦-ចិញ្ចឹមខ្លួនឲ្យបានសុខផង ចាត់ចែងបែងធ្វើបុណ្យទានផង ។

ក្រុមទី ៣ – ស្វែងរកទ្រព្យប្រកបដោយធម៌ បានទ្រព្យមកហើយ ប្រព្រឹត្តដូចនេះ –

៧-មិនចិញ្ចឹមខ្លួនឲ្យបានសុខ មិនចាត់ចែងបែងធ្វើបុណ្យទាន ។

៨-ចិញ្ចឹមខ្លួនឲ្យបានសុខ តែមិនចាត់ចែងបែងធ្វើបុណ្យទាន

៩-ចិញ្ចឹមខ្លួនឲ្យបានសុខផង ចាត់ចែងបែងធ្វើបុណ្យទាន

ផង ប៉ុន្តែ ជុលងប់ ជ្រប់ ឈ្លក់នឹងទ្រព្យសម្បត្តិនោះ មិនឃើញទោស មិនមានបញ្ញារំដោះខ្លួនចាកទ្រព្យសម្បត្តិនោះឡើយ ។

ក្រុមពិសេស – ស្វែងរកទ្រព្យប្រកបដោយធម៌ បានទ្រព្យមកហើយ ប្រព្រឹត្តដូចនេះ –

១០-ចិញ្ចឹមខ្លួនឲ្យបានសុខផង ចាត់ចែងបែងធ្វើបុណ្យទានផង ថែមទាំងមានចិត្តមិនជុលងប់ ជ្រប់ ឈ្លក់នឹងទ្រព្យសម្បត្តិនោះផង ជាអ្នកឃើញទោស និង មានបញ្ញារំដោះខ្លួនចាកទ្រព្យសម្បត្តិនោះបាន ។

បណ្តាអ្នកបរិភោគកាមទាំង ១០ ពួកនេះ អ្នកបរិភោគកាមក្រុមពិសេស គឺទី ១០ នេះ ប្រសើរ ចម្បង ខ្ពង់ខ្ពស់ ថ្លៃថ្លាជាងក្រុមណាៗទាំងអស់[៨] ៕

## ចំណុចអាក្រក់ល្អ ដែលគប្បីចងចាំ

-មិនប្រកបដោយធម៌ គឺ អាក្រក់

-ប្រកបដោយធម៌ គឺ ល្អ

-មិនចិញ្ចឹមខ្លួនឲ្យបានសុខ គឺ អាក្រក់

-ចិញ្ចឹមខ្លួនឲ្យបានសុខ គឺ ល្អ

---

[៨]-សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ៥០-៩១-៣៨៣

-មិនធ្វើបុណ្យទាន គឺ អាក្រក់

-ធ្វើបុណ្យទាន គឺ ល្អ

-ងុលងប់ ជ្រប់ ឈ្លក់ គឺ អាក្រក់

-មិនងុលងប់ ជ្រប់ ឈ្លក់ គឺ ល្អ ។

អ្នកដែលមានសេចក្តីអាក្រក់ច្រើនចំណុចជាងគេ គឺ អ្នកទី១ បន្ទាប់មក មានចំណុចល្អខ្ពស់ឡើងជាលំដាប់ រហូតដល់ទី ១០ ៕

## សិង្គាលកសូត្រ

៙៚

ព្រះមានព្រះភាគ និមន្តទៅបិណ្ឌបាត បានឃើញសិង្គាលកគហបតីបុត្ត ក្រោកឡើងអំពីព្រឹក ថ្វាយបង្គំទិសទាំងឡាយ ខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និង ខាងលើ ទ្រង់ត្រាស់សួរថា ម្នាលគហបតីបុត្ត ហេតុអ្វី ទើបអ្នកថ្វាយបង្គំទិស ។ សិង្គាលកគហបតីបុត្ត ក្រាបទូលថា បពិត្រព្រះអង្គ កាលបិតាខ្ញុំជិតនឹងស្លាប់ គាត់បានផ្តាំឲ្យខ្ញុំព្រះអង្គ ធ្វើសក្ការៈគោរព បូជា ថ្វាយបង្គំទិស ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគហបតីបុត្ត ក្នុងអរិយវិន័យ គេមិនថ្វាយបង្គំទិសទាំង ៦ ដូចនេះទេ ។ សិង្គាលកគហបតីបុត្ត បង្គំទូលសួរថា ក្នុងអរិយវិន័យ គេថ្វាយបង្គំទិសទាំង ៦ ដូចម្តេច សូមព្រះអង្គសំដែងធម៌នោះ ដល់

ខ្ញុំព្រះអង្គផង ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតីបុត្ត អរិយសាវក លះកម្មក្កិលេស (អំពើដ៏សៅហ្មង) ៤ ប្រការផង មិនធ្វើបាបកម្ម ព្រោះហេតុ (អគតិ) ៤ យ៉ាងផង មិនសេព អបាយមុខ ៦ យ៉ាងផង ប្រាសចាកបាបធម៌ទាំង ១៤ យ៉ាងនេះ ជាអ្នកបិទបាំងទិសទាំង ៦ ប្រតិបត្តិដើម្បីជ័យជំនះក្នុងលោក ទាំងពីរ គឺលោកនេះ និង លោកខាងមុខ ។ អរិយសាវកនោះ លុះទំលាយកាយ គេនឹងទៅកើតក្នុងមនុស្ស សួគ៌ទេវលោក ៕

## កម្មក្កិលេស ៤

១-**បាណាតិបាត** សម្លាប់សត្វ

២-**អទិន្នាទាន** លួចទ្រព្យគេ

៣-**កាមេសុ មិច្ឆាចារ** ប្រព្រឹត្តខុសក្នុងកាម

៤-**មុសាវាទ** និយាយកុហក ៕

## អគតិធម៌ ៤

១-**ឆន្ទាគតិ** លំអៀងព្រោះស្រឡាញ់

២-**ទោសាគតិ** លំអៀងព្រោះស្អប់

៣-**មោហាគតិ** លំអៀងព្រោះល្ងង់

៤-**ភយាគតិ** លំអៀងព្រោះខ្លាច ៕

## អបាយមុខ ៦

**១-សុរាមេរយានុយោគ** ប្រកបរឿយៗ នូវការផឹកសុរាមេរ័យ និង គ្រឿងញៀន

**២-វិកាលវិសិខានុយោគ** ប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល

**៣-សមជ្ជាភិចរណំ** ត្រាច់ទៅមើលមហោស្រព

**៤-ជូតានុយោគ** ប្រកបរឿយៗ នូវល្បែងភ្នាល់

**៥-បាបមិត្តានុយោគ** ប្រកបរឿយៗ គឺសេពគប់បាបមិត្រ

**៦-អាលស្សានុយោគ** ប្រកបរឿយៗ គឺខ្ជិលច្រអូស ៕

## ផឹកសុរាមេរ័យមានទោស ៦ យ៉ាង

**១-ធនជានិ** វិនាសទ្រព្យឃើញជាក់ស្តែង

**២-កលហប្បវឌ្ឍនី** បង្កឲ្យកើតជម្លោះ

**៣-រោគានំ អាយតនំ** ជាហេតុនាំឲ្យកើតរោគ

**៤-អកិត្តិសញ្ជននី** ជាការនាំឲ្យខូចឈ្មោះ

**៥-ហិរិកោបិននិទំសនី** ជាការបើកបង្ហាញកេរ្តិ៍ខ្មាស

**៦-បញ្ញាយ ទុព្វលីករណី** ជាការបន្ថយនូវបញ្ញា ។

## ដើរលេងយប់តាមច្រកល្ហកមានទោស ៦ យ៉ាង

**១-អត្តាបិស្ស អគុត្តោ អរក្ខិតោ** មិនគ្រប់គ្រងថែរក្សាខ្លួន។

២-បុត្តទារោ ចិស្ស អគុត្តោ អរក្ខិតោ មិនគ្រប់គ្រង មិនថែរក្សាកូន ប្រពន្ធ ។

៣-សាបតេយ្យំ ចិស្ស អគុត្តំ អរក្ខិតំ មិនគ្រប់គ្រង មិនថែរក្សាទ្រព្យសម្បត្តិ ។

៤-សង្កិយោ ធ្វើឲ្យគេសង្ស័យ ។

៥-អភូតវចនំ ពាក្យមិនពិត ធ្លាក់មកដល់ខ្លួន ។

៦-ទុក្ខធម្មានំ ចុរក្ខិតោ ទុក្ខលំបាកជាច្រើននៅជុំវិញខ្លួន។

## ដើរមើលមហោស្រពមានទោស ៦ យ៉ាង

១-ក្វ នច្ចំ មានរបាំទីណាទៅទីនោះ ។

២-ក្វ គីតំ មានចម្រៀងទីណាទៅទីនោះ ។

៣-ក្វ វាទិតំ មានប្រគំទីណា ទៅទីនោះ ។

៤-ក្វ អក្ខានំ មានដំណាលរឿងទីណាទៅទីនោះ ។

៥-ក្វ បាណិស្សរំ មានប្របកែនៅទីណាទៅទីនោះ ។

៦-ក្វ កុម្ភថូនំ មានដំស្គរទីណាទៅទីនោះ ។

## លេងល្បែងភ្នាល់មានទោស ៦ យ៉ាង

១-ជយំ វេរំ បសវតិ កាលបើឈ្នះ តែងមានពៀរ ។

២-ជិនោ វិត្តមនុសោចតិ កាលបើចាញ់ តែងសោក ស្តាយទ្រព្យ ។

៣-**សន្និដ្ឋិកា ធនជានិ** វិនាសទ្រព្យឃើញជាក់ស្តែង ។

៤-**សភាគតស្ស វចនំ ន រូហតិ** កាលបើទៅកាន់ទីប្រជុំ និយាយអ្វី គេមិនស្តាប់ ។

៥-**មិត្តាមច្ចានំ បរិត្តោ** មិត្រអាមាត្រគេមើលងាយ ។

៦-**អាវាហវិវាហកានំ អប្បត្ថិតោ** គេមិនត្រូវការដណ្តឹងយកទៅជាគូគ្រង ។

## សេពគប់បាបមិត្រមានទោស ៦ យ៉ាង

១-**យេ ធុត្តា** ទៅជាអ្នកលេងល្បែងភ្នាល់ ។

២-**យេ សោណ្ឌា** ទៅជាអ្នកលេងស្រី ។

៣-**យេ បិបាសា** ទៅជាអ្នកប្រមឹក ។

៤-**យេ នេកតិកា** ទៅជាអ្នកក្លែងបោកបញ្ឆោត ។

៥-**យេ វញ្ចនិកា** ទៅជាអ្នកគេងប្រវ័ញ្ច ។

៦-**យេ សហសិកា** ទៅជាអ្នកឆក់ដណ្តើម ។

## អ្នកខ្ជិលច្រអូសមានទោស ៦ យ៉ាង

១-**អតិសីតំ** អាងថា ត្រជាក់ពេក មិនធ្វើការងារ ។

២-**អតិឧណ្ហំ** អាងថា ក្តៅពេក មិនធ្វើការងារ ។

៣-**អតិសាយំ** អាងថា ល្ងាចពេក មិនធ្វើការងារ ។

៤-**អតិបាតោ** អាងថា ព្រឹកពេក មិនធ្វើការងារ ។

៥-**អតិច្ឆាតោ** អាងថា ឃ្លានពេក មិនធ្វើការងារ ។

៦-**អតិបិបាសិតោ** អាងថា ស្រេកពេក មិនធ្វើការងារ ។

បើគេអាងទោស ៦ យ៉ាងនេះហើយ មិនធ្វើការងារ ទ្រព្យសម្បត្តិទាំងឡាយ ដែលមិនទាន់កើតឡើង កើតឡើងមិនបាន ទ្រព្យសម្បត្តិទាំងឡាយ ដែលកើតឡើងហើយ វិនាសរេចរឹលទៅវិញ ។

## មិត្តបដិរូប មិត្តប្លម ៤ យ៉ាង

១-**អញ្ញទត្ថុហរោ** មិត្រគិតយកតែប្រយោជន៍ខ្លួន ។

២-**វចីបរមោ** មិត្រល្អតែសំដី ។

៣-**អនុប្បិយភាណី** មិត្រនិយាយចាក់បណ្ដោយ(ប្រចុប)។

៤-**អបាយសហាយោ** មិត្រ(បបួល)ក្នុងរឿងនាំឲ្យវិនាស។

### អញ្ញទត្ថុហរោ មានលក្ខណៈ ៤ យ៉ាង

៤-**អញ្ញទត្ថុហរោ** មិត្រគិតតែយកប្រយោជន៍ខ្លួន ។

២-**អប្បេន ពហុមិច្ឆតិ** ឲ្យតិចចង់បានច្រើន ។

៣-**ភយស្ស កិច្ចំ ន ករោតិ** មិត្រមានភ័យ មិនជួយ។

៤-**សេវតិ អត្ថការណា** សេពគប់មិត្រព្រោះហេតុតែប្រយោជន៍ ។

**វចីបរម** មានលក្ខណៈ ៤ យ៉ាង

១-**អតីតេន បដិសន្ថរតិ** ទទួលរាក់ទាក់ ដោយរបស់ដែលកន្លងហើយ ។

២-**អនាគតេន បដិសន្ថរតិ** ទទួលរាក់ទាក់ ដោយរបស់ដែលមិនទាន់មកដល់ ។

៣-**និរត្ថកេន សង្គណ្ហាតិ** សង្គ្រោះដោយរបស់ ឥតប្រយោជន៍ ។

៤-**ព្យសនំ ទស្សេតិ** កាលមិត្រមានកិច្ចធុរៈកើតឡើងប្រាប់ (គួញ) តែរឿងខូចខាត ។

**អនុប្បិយភាណី** មានលក្ខណៈ ៤ យ៉ាង

១-**បាបកម្មំបិស្ស អនុជានាតិ** មិត្រធ្វើអាក្រក់ បណ្ដោយតាម (អើ) ។

២-**កល្យាណំបិស្ស អនុជានាតិ** មិត្រធ្វើល្អ បណ្ដោយតាម ។

៣-**សម្មុខស្ស វណ្ណំ ភាសតិ** ចំពោះមុខពោលសរសើរ។

៤-**បរម្មុខស្ស អវណ្ណំ ភាសតិ** កំបាំងមុខ ពោលនិន្ទា។

**អបាយសហាយោ** មានលក្ខណៈ ៤ យ៉ាង

១-**សុរាមេរយសហាយោ** ជាសម្លាញ់ក្នុងការផឹកសុរាមេរ័យ

២-**វិកាលវិសិខាសហាយោ** ជាសម្លាញ់ក្នុងការដើរលេងយប់តាមច្រកល្ហក ។

៣-**សមជ្ជាភិចរណសហាយោ** ជាសម្លាញ់ក្នុងការដើរមើលមហោស្រព ។

៤-**ជូតសហាយោ** ជាសម្លាញ់ក្នុងការលេងល្បែងភ្នាល់ ។

មិត្របួម ៤ យ៉ាងនេះ បុគ្គលគប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរចៀសវាងផ្លូវដែលប្រកបដោយភ័យ ដូចនោះ ។

**សុហទា** មិត្រមានសន្ដានល្អ(ពិត) ៤ យ៉ាង

១-**ឧបការក** មិត្រមានឧបការៈ ។

២-**សមានសុខទុក្ខ** មិត្ររួមសុខទុក្ខ ។

៣-**អត្ថក្ខាយី** មិត្រប្រាប់ប្រយោជន៍ ។

៤-**អនុកម្បក** មិត្រមានសេចក្ដីឈឺឆ្អាល ។

**ឧបការក** មានលក្ខណៈ ៤ យ៉ាង

១-**បមត្តំ រក្ខតិ** រក្សាមិត្រដែលធ្វេសប្រហែស ។

២-**បមត្តស្ស សាបតេយ្យំ រក្ខតិ** រក្សាទ្រព្យសម្បត្តិមិត្រដែលធ្វេសប្រហែស ។

៣-**ភីតស្ស បដិសរណំ ហោតិ** ជាទីពឹងនៃមិត្រដែលមានភ័យ ។

៤-**តទ្ទិគុណំ ភោគំ អនុប្បទេតិ** កាលមិត្រមានកិច្ចធុរៈជួយផ្តល់ភោគៈជាទ្វិគុណ ។

**សមានសុខទុក្ខ** មានលក្ខណៈ ៤ យ៉ាង

១-**គុយ្ហមស្ស អាចិក្ខតិ** ប្រាប់អាថ៌កំបាំងរបស់ខ្លួន ។

២-**គុយ្ហមស្ស បរិគុយ្ហតិ** បិទបាំងអាថ៌កំបាំងរបស់មិត្រ ។

៣-**អាបទាសុ ន វិជហាតិ** មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ។

៤-**ជីវិតំបិស្ស អត្ថាយ បរិច្ចត្តំ ហោតិ** សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍មិត្រ ។

**អត្ថក្ខាយី** មានលក្ខណៈ ៤ យ៉ាង

១-**បាបា និវារេតិ** ហាមមិត្រចាកអំពើអាក្រក់ ។

២-**កល្យាណេ និវេសេតិ** ឲ្យមិត្រតាំងនៅក្នុងអំពើល្អ ។

៣-**អស្សុតំ សាវេតិ** ឲ្យមិត្របានស្តាប់អ្វី ដែលមិនធ្លាប់ស្តាប់ ។

៤-**សគ្គស្ស មគ្គំ អាចិក្ខតិ** ប្រាប់ផ្លូវស្ថានសួគ៌ ។

**អនុកម្បក** មានលក្ខណៈ ៤ យ៉ាង

១-**អភវេនស្ស ន នន្ទតិ** ព្រួយចិត្តព្រោះមិត្រមានសេចក្ដីវិនាស ។

២-**ភវេនស្ស នន្ទតិ** សប្បាយចិត្តព្រោះមិត្របានចំរើន ។

៣-**អវណ្ណំ ភណមានំ និវារេតិ** ហាមឃាត់អ្នកដែលនិន្ទាមិត្រ ។

៤-**វណ្ណំ ភណមានំ បសំសតិ** សរសើរអ្នកដែលសរសើរមិត្រ ។

បុគ្គលគប្បីសេពគប់រាប់រកស្និទ្ធស្នាល ជាមួយមិត្រមានសន្ដានល្អ ដូចជាមាតា និង បុត្រ ។

## ទិស ៦

### ១-មាតាបិតា ជាទិសខាងកើត

កូនត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាង គឺ:

(១)-**ភតោ នេសំ ភរិស្សាមិ** អាត្មាអញ មាតា-បិតា បានចិញ្ចឹមហើយ នឹងចិញ្ចឹមលោកវិញ ។

(២)-**កិច្ចំ នេសំ ករិស្សាមិ** អាត្មាអញនឹងជួយធ្វើការងារមាតាបិតាវិញ ។

(៣)-**កុលវំសំ ឋបេស្សាមិ** អាត្មាអញនឹងតម្កល់ វង្ស

ត្រកូលទុកឲ្យបានល្អ ។

(៤)-**ទាយជ្ជំ បដិបជ្ជាមិ** អាត្មាអញនឹងបដិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌ក ។

(៥)-**បេតានំ កាលកតានំ ទក្ខិណំ អនុប្បទស្សាមិ** អាត្មាអញនឹងធ្វើទក្ខិណានុប្បទាន ដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ។

មាតាបិតា ត្រូវអនុគ្រោះកូនដោយស្ថាន ៥ យ៉ាង គឺៈ

(១)-**បាបា និវារេន្តិ** ហាមឃាត់កូនចាកអំពើអាក្រក់ ។

(២)-**កល្យាណេ និវេសេន្តិ** ឲ្យកូនតាំងនៅក្នុងអំពើល្អ ។

(៣)-**សិប្បំ សិក្ខាបេន្តិ** ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ។

(៤)-**បតិរូបេន ទារេន សញ្ញោជេន្តិ** រកភរិយាស្វាមីសមគួរឲ្យ ។

(៥)-**សមយេ ទាយជ្ជំ និយ្យាទេន្តិ** ចែកទ្រព្យឲ្យកូនក្នុងសម័យដ៏សមគួរ ។

## ២-គ្រូអាចារ្យ ជាទិសខាងត្បូង

សិស្សត្រូវបដិបត្តិដោយស្ថាន ៥ យ៉ាង គឺៈ -

(១)-**ឧដ្ឋានេន** ដោយការក្រោកទទួល ។

(២)-**ឧបដ្ឋានេន** ដោយការគាល់បំរើ ។

(៣)-**សុស្សូសាយ** ដោយការជឿស្តាប់ឱវាទ ។

(៤)-**សាមិចរិយាយ** ដោយការបំរើតូចៗ ។

(៥)-**សក្កច្ចំ សិប្បំ បដិគ្គហណេន** ដោយការរៀនសិល្ប សាស្ត្រដោយគោរព ។

គ្រូអាចារ្យ ត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាង គឺៈ

(១)-**សុវិនីតំ វិនេន្តិ** ដឹកនាំល្អ ។

(២)-**សុគ្គហិតំ គាហាបេន្តិ** បង្រៀនល្អ ។

(៣)-**សព្វសិប្បស្សុតំ សមក្ខាយិនោ ភវន្តិ** ប្រៀនប្រដៅសិស្សឲ្យចេះគ្រប់សិល្បសាស្ត្រ ។

(៤)-**មិត្តាមច្ចេសុ បដិវេទេន្តិ** លើកតម្កើងក្នុងទីប្រជុំមិត្រអាមាត្រ ។

(៥)-**ទិសាសុ បរិត្តំ ករោន្តិ** ធ្វើសេចក្តីការពារគ្រប់ទិសទី ។

៣-ភរិយា ជាទិសខាងលិច

ស្វាមី ត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាង គឺៈ -

(១)-**សម្មានោនាយ** ដោយការរាប់អានជាភរិយាពេញទី ។

(២)-**អវិមាននាយ** ដោយការមិនមើលងាយ ។

(៣)-**អនតិចរិយាយ** ដោយការមិនប្រព្រឹត្តក្បត់ចិត្ត ។

(៤)-**ឥស្សរិយវោស្សគ្គេន** ដោយការប្រគល់ឲ្យជាធំក្នុងផ្ទះ ។

(៥)-**អលង្ការានុប្បទានេន** ដោយការឲ្យគ្រឿងអលង្ការ ។

ភរិយា ត្រូវអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាង គឺៈ

(១)-**សុសំវិហិតកម្មន្តា** ចាត់ចែងការងារឲ្យបានល្អ ។

(២)-**សុសង្គហិតបរិជនា** សង្គ្រោះញាតិទាំងពីរខាងបានល្អ

(៣)-**អនតិចារិនី** មិនប្រព្រឹត្តក្បត់ចិត្ត ។

(៤)-**សម្ភតំ អនុរក្ខតិ** ថែរក្សាទ្រព្យទុកឲ្យបានល្អ ។

(៥)-**សព្វកិច្ចេសុ ទក្ខា អនលសា** ឈ្លាសវៃមិនខ្ជិលច្រអូសក្នុងកិច្ចការសព្វយ៉ាង ។

## ៤-មិត្តអាមាត្រ ជាទិសខាងជើង

កុលបុត្រ ត្រូវបដិបត្តិដោយស្ថាន ៥ យ៉ាង គឺៈ -

(១)-**ទានេន** ដោយការឲ្យរបស់ទ្រព្យ ។

(២)-**បិយវជ្ជេន** ដោយការនិយាយពាក្យផ្អែមល្ហែម ។

(៣)-**អត្ថចរិយាយ** ដោយការប្រព្រឹត្តជាប្រយោជន៍ ។

(៤)-**សមានត្តតាយ** ដោយការប្រព្រឹត្តខ្លួនស្មើ ។

(៥)-**អវិសំវាទនតាយ** ដោយការមិនកុហកបញ្ឆោត ។

### មិត្តអាមាត្រ

ត្រូវអនុគ្រោះកុលបុត្រដោយស្ថាន ៥ យ៉ាងគឺៈ -

(១)-**បមត្តំ រក្ខន្តិ** រក្សាមិត្រដែលធ្វេសប្រហែស ។

(២)-**បមត្តស្ស សាបតេយ្យំ រក្ខន្តិ** រក្សាទ្រព្យសម្បត្តិមិត្ត ដែលធ្វេសប្រហែស ។

(៣)-**ភីតស្ស សរណំ ហោន្តិ** ជាទីពឹងរបស់មិត្តដែល មានភ័យ ។

(៤)-**អាបទាសុ ន ជហន្តិ** មិនបោះបង់គ្នាក្នុងគ្រាមាន វិបត្តិ ។

(៥)-**អបរបជំបិស្ស បដិបូជេន្តិ** រាប់អានរហូតដល់ ផៅ-ពង្សរបស់មិត្ត ។

៥-**ទាសកម្មករ** ជាទិសខាងក្រោម

ចៅហ្វាយនាយ ត្រូវទំនុកបំរុងដោយស្ថាន ៥ យ៉ាង

(១)-**យថាពលំ កម្មន្តំ សំវិធានេន** ដោយការចាត់ចែង ការងារឲ្យសមគួរដល់កម្លាំង ។

(២)-**ភត្តវេតនានុប្បទានេន** ដោយការឲ្យភត្តាហារ និងថ្លៃឈ្នួលសមរម្យ ។

(៣)-**គិលានុបដ្ឋានេន** ដោយការជួយព្យាបាលក្នុងពេល ឈឺថ្កាត់ ។

(៤)-**អច្ឆរិយានំ រសានំ សំវិភាគេន** ដោយការចែក រំលែករបស់ដែលមានរសជាតិប្លែកៗ (ឆ្ងាញ់) ។

(៥)-**សមយេ វោសជ្ជេន** ដោយការឲ្យឈប់សម្រាកក្នុងសម័យដ៏គួរ ។

**ទាសកម្មករ** ត្រូវអនុគ្រោះចៅហ្វាយនាយ
ដោយស្ថាន ៥ យ៉ាង

១-**បុព្វុដ្ឋាយិនោ** ត្រូវក្រោកឡើងធ្វើការមុន ។

២-**បច្ឆានិបាតិនោ** ត្រូវឈប់ធ្វើការក្រោយ ។

៣-**ទិន្នាទាយិនោ** កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ ។

៤-**សុកតកម្មករា** ធ្វើការដោយយកចិត្តទុកដាក់ ។

៥-**កិត្តិវណ្ណហរា** សរសើរគុណរបស់ចៅហ្វាយនាយ ។

**៦-សមណព្រាហ្មណ៍** ជាទិសខាងលើ
កុលបុត្រត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាង

១-**មេត្តាកាយកម្មេន** កាយកម្ម ប្រកបដោយមេត្តា ។

២-**មេត្តាវចីកម្មេន** វចីកម្ម ប្រកបដោយមេត្តា ។

៣-**មេត្តាមនោកម្មេន** មនោកម្ម ប្រកបដោយមេត្តា ។

៤-**អនាវដទ្វារតាយ** មិនបិទទ្វារផ្ទះ ។

៥-**អាមិសានុប្បទានេន** ឲ្យអាមិសទាន ។

## **សមណព្រាហ្មណ៍** ត្រូវអនុគ្រោះកុលបុត្រ ដោយស្ថាន ៦ យ៉ាង

១-**បាបា និវារេន្តិ** ហាមឃាត់ចាកអំពើអាក្រក់ ។

២-**កល្យាណេ និវេសេន្តិ** ឲ្យតាំងនៅក្នុងអំពើល្អ ។

៣-**កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះដោយទឹកចិត្តដ៏ល្អ ។

៤-**អស្សុតំ សាវេន្តិ** ឲ្យបានស្ដាប់ធម៌ ដែលមិនធ្លាប់បានស្ដាប់ ។

៥-**សុតំ បរិយោទបេន្តិ** បំភ្លឺធម៌ដែលធ្លាប់បានស្ដាប់-ហើយ ឲ្យកាន់តែច្បាស់ឡើង ។

៦-**សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវទៅស្ថានសួគ៌ ។

ទិសទាំង ៦ នេះ ដែលគេបាននាំគ្នាបដិបត្តិ តាមនាទីត្រឹមត្រូវល្អសព្វគ្រប់ហើយ ឈ្មោះថាបានបិទបាំងហើយ ជាទិសក្សេមក្សាន្ត មិនមានទុក្ខភ័យអ្វីឡើយ ។

## **សង្គហធម៌ ៤ យ៉ាង**

១-**ទាន** ការឲ្យទាន ការលះបង់ ។

២-**បិយវាចា** សំដីសុភាព ផ្អែមល្ហែម នាំឲ្យកើតសាមគ្គីភាពល្អ ។

៣-**អត្ថចរិយា** ការប្រព្រឹត្តជាប្រយោជន៍ ។

៤-**សមានត្តតា** ភាពជាអ្នកមានខ្លួនស្មើ អាចទាក់ទងគ្នាបានល្អ ។

មនុស្សលោក មានគុណសម្បត្តិ សមត្ថភាព មិនដូចគ្នា មិនស្មើគ្នាទេ ។ មនុស្សត្រូវចេះជួយសង្គ្រោះគ្នា វិធីជួយសង្គ្រោះត្រូវប្រព្រឹត្តទៅតាមគោលធម៌ ៤ ប្រការនេះ ។ សង្គមមនុស្សប្រព្រឹត្តទៅបានស្រួល ដោយអាស្រ័យសង្គហធម៌នេះ ដូចជារទេះដែលមានប្រែកទប់ដូច្នោះឯង ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងយ៉ាងនេះហើយ សិង្គាលកគហបតីបុត្ត ក្រាបបង្គំទូលយ៉ាងនេះថា ពីរោះណាស់ៗ ដូចជាគេផ្ងាររបស់ដែលគេផ្កាប់ ដូចជាគេបើកបង្ហាញរបស់ដែលគេបិទបាំង ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេង ឬដូចជាគេអុជប្រទីបទ្រោលក្នុងទីងងឹត ខ្ញុំព្រះអង្គ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង សូមព្រះអង្គ ទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជា ឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់តាំងពីថ្ងៃនេះរៀងទៅ[៩] ៕

---

[៩]-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ១៩-៤៣-៦៧

## គួរសង្កេត

១-ក្នុង កម្មក្កិលេស មានតែ ៤ មិនឃើញមានសុរាមេរ័យ។ អ្នកខ្លះយល់ថា សុរាមេរ័យ ប្រហែលជាមិនសូវសំខាន់ទេ បានជាព្រះអង្គមិនដាក់មក ដូចនេះ ផឹកក៏បាន ។ កុំ កុំ ! ច្រឡំហើយ ច្រឡំធំហើយ ។ សុរាមេរ័យ សំខាន់ណាស់ ព្រះពុទ្ធអង្គទ្រង់មិនដាក់ចូលក្នុង កម្មក្កិលេស មែន ប៉ុន្តែ ព្រះអង្គ ដាក់ចូលក្នុងអបាយមុខ ។ នេះ ជាវិធីឆ្លាតមួយបែប ដែលនាំមនុស្សកាន់សីល ៥ ដោយមិនបាច់ប្រាប់ថាសីល ។

២-ក្នុងព្រះសូត្រនេះ មានពាក្យថា ឧភោលោកវិជ័យ ឈ្នះលោកទាំងពីរ បានសេចក្តីថា បើគេបដិបត្តិតាមព្រះសូត្រនេះបាន ក្នុងបច្ចុប្បន្ន គេរាប់ថាជាមនុស្សល្អ (ឈ្នះ) លុះស្លាប់ទៅកើតក្នុងជាតិមុខ គេក៏ត្រូវកើតក្នុងកំណើតល្អ (ឈ្នះទៀត) ។

៣-ពួកបស្ចិមប្រទេស គេមិនមែនជា ពុទ្ធបរិស័ទ ទេ ប៉ុន្តែគេចាប់អារម្មណ៍ព្រះសូត្រនេះ គេឲ្យតម្លៃព្រះសូត្រនេះច្រើនណាស់ ។ ចំណែកឯ ពួកយើងជា ពុទ្ធបរិស័ទ ត្រឡាំង បែរជាមិនសូវចាប់អារម្មណ៍ព្រះសូត្រនេះ អ្នកខ្លះបែបមើលរំលងទៅផង។

ភ្ញាក់រលឹកឡើង យើងនឹងថ្កុំថ្កើង
រុងរឿងសប្បាយ ឈ្នះទាំងលោកនាយ
ឈ្នះទាំងលោកអាយ អស់អន្តរាយ
ដោយសារសូត្រនេះ ៕

# អាឡវកសូត្រ

## ឃរាវាសធម៌

ធម៌របស់អ្នកគ្រប់គ្រងផ្ទះ ៤ យ៉ាង

១-**សច្ចះ** សេចក្ដីស្មោះត្រង់ សេចក្ដីទៀងត្រង់ ចំពោះគ្រួសារក្ដី ចំពោះអ្នកដទៃក្ដី ចំពោះមុខនាទីរបស់ខ្លួនក្ដី ។

២-**ទមះ** ការអប់រំខ្លួន ទប់ខ្លួន ហ្វឹកហាត់ខ្លួន ឲ្យស្ទាត់-ជំនាញក្នុងកិច្ចការផ្សេងៗក្ដី ទប់ចិត្តកុំឲ្យកិលេសអូសទាញទៅក្នុងផ្លូវអាក្រក់ក្ដី ។

៣-**ខន្តិ** សេចក្ដីអត់ធន់ តស៊ូ ក្ដៅ ត្រជាក់ ស្រេកឃ្លាន ឈឺ ផ្ដាត់ ឬ សត្វ មូស សុច ជាដើមបៀតបៀន ។

៤-**ចាគះ** ការលះបង់ទ្រព្យចិញ្ចឹមខ្លួន មាតាបិតា កូនប្រពន្ធ ឬ ធ្វើបុណ្យទានផ្សេងៗក្ដី លះគំនុំគុំគួន ឬលះកិលេសមច្ឆរិយៈ សេចក្ដីកំណាញ់ជាដើមក្ដី[១០] ។

អ្នកគ្រប់គ្រងផ្ទះ ត្រូវមានធម៌ ៤ នេះ ទើបមានការកក់ក្ដៅ បើខ្វះធម៌ ៤ យ៉ាងនេះ ពិតជារងា (មានបញ្ហា) ហើយ ។

---

[១០]-សុត្តន្តបិដក សំយុត្តនិកាយ សគាថវគ្គ ៣០-៣២៤-២៣៤

## ភោគវិភាគ

ការបែងចែកភោគៈ

ទ្រព្យដែលរកបានមក ត្រូវចែកជា ៤ ចំណែកគឺៈ

១-ឯកេន ភោគេ ភុញ្ជេយ្យ មួយភាគសំរាប់ចិញ្ចឹមខ្លួន និងបុគ្គលដែលត្រូវចិញ្ចឹម ។

២-ទ្វីហិ កម្មំ បយោជយេ

៣-ពីរភាគសំរាប់ធ្វើដើមទុន ប្រកបការងារ ។

៤-ចតុត្ថញ្ច និធាបេយ្យ មួយភាគ ទុកការពារ ពេលមានអាសន្ន អន្តរាយ(១១) ។

បើគេបានលៃបែងចែកទ្រព្យជាចំណែកដូចនេះ (សូម្បីមិនបានដូចមួយរយភាគរយ) ក៏សង្ឃឹមថា គេនឹងមានសេចក្ដីសុខ មិនខ្វះខាត មិនជំពាក់បំណុលឡើយ ។

ឯកេន ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ
ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតិ ។

---

(១១)-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ សិង្គាលកសូត្រ ១៩-៦៨-៨៣

## **កុលចិរដ្ឋិតិធម៌**

ត្រកូលស្តុកស្តម្ភ នៅស្ថិតស្ថេរបានយូរ
ដោយធម៌៤ យ៉ាង

១-**នដ្ឋគវេសនា** ស្វែងរករបស់ដែលបាត់ ។

២-**ជិណ្ណប្បដិសង្ខរណា** ជួសជុលរបស់ដែលចាស់ ។

៣-**បរិមិតបានភោជនា** ស្គាល់ប្រមាណក្នុងការបរិភោគ។

៤-**អធិបច្ចសីលវន្តស្ថាបនា** តាំងស្ត្រីឬបុរសអ្នកមានសីលជាធំ[១២] ។

## **ឥទ្ធិបាទធម៌**

ធម៌ជាហេតុនាំឲ្យបានសម្រេចផល៤ យ៉ាង

១-**ឆន្ទ** សេចក្តីពេញចិត្ត ។

២-**វីរិយះ** សេចក្តីព្យាយាម ។

៣-**ចិត្ត** ការយកចិត្តទុកដាក់ ។

៤-**វិមំសា** សេចក្តីត្រិះរិះ ពិចារណា[១៣] ។

---

[១២]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤៣-១០៨-២៧០

[១៣]-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ១៩-១០២-១៤៨

# សារាណីយសូត្រ

សារាណីយធម៌ ៦ យ៉ាង

១-**មេត្តាកាយកម្ម** កាយកម្មប្រកបដោយមេត្តា ។

២-**មេត្តាវចីកម្ម** វចីកម្មប្រកបដោយមេត្តា ។

៣-**មេត្តាមនោកម្ម** មនោកម្មប្រកបដោយមេត្តា ។

៤-**សាធារណភោគី** បានអ្វីមកប្រើជាសាធារណៈ ។

៥-**សីលសាមញ្ញតា** មានសីលធម៌ស្មើគ្នា ។

៦-**ទិដ្ឋិសាមញ្ញតា** មានទិដ្ឋិរួមស្មើគ្នា ។

**សារាណីយធម៌** ធម៌ធ្វើឲ្យគេនឹករលឹក **បិយករណា** ធ្វើឲ្យគេស្រឡាញ់ **គរុករណា** ធ្វើឲ្យគេគោរព **សង្គហាយ** ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា **អវិវាទាយ** ដើម្បីមិនទាស់ទែងគ្នា **សាមគ្គិយា** ដើម្បីសាមគ្គី **ឯកីភាវាយ** ដើម្បីឯកភាពគ្នា(១៤) ៕

# សត្តិសូត្រ

សប្បុរិសធម៌ ៧

១-**ធម្មញ្ញូតា** ស្គាល់ហេតុ ។

---

(១៤)-សុត្តន្តបិដក អង្គុត្តរនិកាយ ឆក្កនិបាត ៤៦-១២-២១

២-**អត្ថញ្ញុតា** ស្គាល់ផល ។

៣-**អត្តញ្ញុតា** ស្គាល់ខ្លួន ។

៤-**មត្តញ្ញុតា** ស្គាល់ប្រមាណ ។

៥-**កាលញ្ញុតា** ស្គាល់កាល ។

៦-**បរិសញ្ញុតា** ស្គាល់បរិស័ទ (ប្រជុំជន) ។

៧-**បុគ្គលញ្ញុតា** ស្គាល់បុគ្គល (ប្រភេទមនុស្ស)[១៥]។

មនុស្សល្អ ត្រូវចេះ ត្រូវយល់ធម៌ ៧ ប្រការនេះ ហើយបដិបត្តិតាមធម៌នេះ ឲ្យបានត្រឹមត្រូវ ៕

## ទសពិធរាជធម៌

ធម៌របស់ព្រះរាជា ធម៌របស់អ្នកគ្រប់គ្រង ១០ យ៉ាង

១-**ទាន** ការឲ្យទាន ។

២-**សីល** ការរក្សាសីល ។

៣-**បរិច្ចាគ** លះបង់ទ្រព្យ សេចក្តីសុខ និងជីវិតដើម្បីជាតិ ។

៤-**អាជ្ជវៈ** សេចក្តីស្មោះត្រង់ ។

---

[១៥]-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ១៩-២០២-២១១

៥-**មទ្ទវៈ** សេចក្តីសុភាព ទន់ភ្លន់ ។

៦-**តបៈ** ការដុតកិលេសរបស់ខ្លួន និង ដុតមន្ត្រីខិលខូច ។

៧-**អក្កោធ** ការមិនក្រេវក្រោធ មានមេត្តា ។

៨-**អវិហឹសា** ការមិនបៀតបៀន មានករុណា ។

៩-**ខន្តិ** សេចក្តីអត់ធន់ ។

១០-**អវិរោធនៈ** ចិត្តរឹងមាំ មិនឃ្លាតចាកគន្លងធម៌[១៦] ។

## ចក្កវត្តិសូត្រ

### ចក្កវត្តិវត្ត

វត្តរបស់ស្តេចចក្រពត្តិ ៥ យ៉ាង

១-**ធម្មាធិបតេយ្យ** តាំងនៅក្នុងធម៌ យកធម៌ជាធំ ។

២-**ធម្មិការក្ខា** គ្រប់គ្រងប្រជាជនប្រកបដោយធម៌ មើលសុខទុក្ខមិនចំពោះតែមនុស្សប៉ុណ្ណោះទេ រហូតដល់សព្វសត្វផង ។

៣-**មា អធម្មការ** ការពារមិនឲ្យអធម៌កើតឡើង ។

៤-**ធនានុប្បទាន** ចែកជូនទ្រព្យសម្បត្តិដល់ជនអ្នកក្រីក្រ។

៥-**បរិបុច្ឆា** សាកសួរព្រះសង្ឃ ឬអ្នកប្រាជ្ញធំៗ ដើម្បីរកគោលធម៌ល្អៗ យកមកអនុវត្តឲ្យកាន់តែបានសុខចំរើនឡើងទៀត[១៧] ។

---

[១៦]-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ៦១-២៤០-១២៨

[១៧]-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ១៨-៣៥-១២០

# កូដទន្តសូត្រ

៣*៧

កូដទន្តព្រាហ្មណ៍ បានចាត់ចែងត្រៀមគោឈ្មោល ៧០០ កូនគោឈ្មោល ៧០០ កូនគោញី ៧០០ ពពែ ៧០០ ចៀម ៧០០ នឹងធ្វើពិធីបូជាយញ្ញ ដើម្បីឲ្យបានសុខសប្បាយ ។ ជួនជាពេលនោះ គាត់បានឃើញប្រជាជននាំគ្នាដើរទៅគាល់ ព្រះសម្មាសម្ពុទ្ធ។ គាត់បានឃាត់គេឲ្យចាំគាត់ផង គាត់នឹងទៅគាល់ព្រះពុទ្ធដែរ ព្រោះគាត់ចង់ដឹងពិធីបូជាយញ្ញ ។ លុះគាត់បានចូលទៅគាល់ព្រះពុទ្ធ ក្រាបបង្គំទូលសួរពិធីបូជាយញ្ញ ព្រះពុទ្ធទ្រង់ត្រាស់ថា ស្រុកទេសកំពុងមានចម្រូងចម្រាស មានការបៀតបៀនគ្នា មានពួកចោរធ្វើបាបអ្នកស្រុកជាដើម ។ បើយើង ទៅបង្ក្រាបត្រង់ៗ មិនបានផលល្អទេ គប្បីធ្វើពិធីដូចតទៅនេះវិញៈ

១-ប្រជាជនទីទ័លក្រ យើងត្រូវចែកដីធ្លី ពូជស្រូវ ពូជដំណាំផ្សេងៗឲ្យគេបង្កបង្កើនផល ។

២-យើងត្រូវឲ្យជាប្រាក់កម្ចីដល់អ្នកជំនួញ ដើម្បីគេធ្វើជាដើមទុន ។

៣-យើងត្រូវឲ្យប្រាក់ខែអ្នករាជការ ឲ្យបានគ្រប់គ្រាន់ កុំឲ្យពួកគេពិបាកខ្វល់ក្នុងរឿងជីវភាពទៀត ។

បើយើងដោះស្រាយបញ្ហាដូចនេះ ជាដើម ស្រុកទេសយើង

នឹងបានសុខសប្បាយ មិនបាច់បូជាយញ្ញក៏បាន ។ កូដទន្តព្រាហ្មណ៍ទូលសួរតទៅទៀតថា មានពិធីអ្វីប្រសើរជាងនេះទៀតដែរទេ ព្រះពុទ្ធទ្រង់ត្រាស់ថា យើងត្រូវមានសីលធម៌ កាន់សីល កាន់ធម៌ឲ្យបានច្រើន ឲ្យបានខ្ពស់ឡើងៗ គ្រប់ៗគ្នាទៅ ស្រុកទេសយើងនឹងរឹតតែបានសុខ-ចំរើន ត្រជាក់ត្រជុំ ក្សេមក្សាន្តជាភិយ្យោភាពរៀងរហូតទៅ[១៨] ៕

## គួរគិតពិចារណា

១-ចង់បានសុខសប្បាយ ធ្វើពិធីបួងសួង បន់ស្រន់ បូជាយញ្ញជាដើម ។ តើសមហេតុផលឬទេ ? ឆ្លាតឬទេ ? គួរធ្វើតទៅទៀតឬទេ ?

២-ចង់បានសុខ-ចំរើន បំបិទសិទ្ធិគេ ធ្វើបាបគេ សម្លាប់គេ តើបានសុខ-ចំរើន ពិតប្រាកដឬទេ ? ត្រឹមត្រូវតាមច្បាប់តាមគន្លងធម៌ឬទេ ?

៣-ស្រុកយើង មានលោកសង្ឃខ្លះ ស្លៀកស្បង់ ពាក់ចីពរជាពុទ្ធសាសនា ប៉ុន្តែ បំរើសាសនាព្រាហ្មណ៍ ស្រោចទឹក រំដោះគ្រោះ លើករាសី... ពួកអ្នកអស់ហ្នឹងហើយ ដែលនាំឲ្យជាតិ

---

[១៨]-សុត្តន្តបិដក ទីឃនិកាយ កូដទន្តសូត្រ ១៥-១-១

សាសនា ថៅកទាប សាបសូន្យ ។

៤-មានវិធីដោះស្រាយតែមួយ គឺជួយសង្គម ដូចព្រះពុទ្ធ បានសម្តែងប្រាប់ កូដទន្តព្រាហ្មណ៍ ប៉ុណ្ណោះទេ ដែលនាំឲ្យជាតិ សាសនា បានសុខ ចំរើន ពិតប្រាកដ ។

ល្អមឈប់ធ្វើផ្តេសផ្តាស ល្អមឈប់គិតរត់ចោលស្រុក ទៅរកសុខក្នុងស្ថានសួគ៌... ។ ត្រូវនាំគ្នាខំជួយកសាងសេចក្តីសុខ ចំរើន ក្នុងស្រុកមនុស្សនេះ ទើបប្រសើរ ៕

## វឌ្ឍិសូត្រ

**ព្រះពុទ្ធ** ទ្រង់ត្រាស់សម្តែងថា -

ម្នាលភិក្ខុទាំងឡាយ អរិយសាវក កាលចំរើនដោយ សេចក្តីចំរើន ១០យ៉ាង រមែងចំរើនដោយសេចក្តីចំរើនដ៏ប្រសើរ ឈ្មោះថា អ្នកកាន់យកនូវខ្លឹម កាន់យកនូវរបស់ដ៏ប្រសើរ នៃរូបកាយ ។

### សេចក្តីចំរើន ១០ យ៉ាងនោះគឺៈ

១-**ខេត្តវត្ថូហិ** ចំរើនដោយស្រែនិងចំការ ។

២-**ធនធញ្ញេន** ចំរើនដោយទ្រព្យ និង ស្រូវ ។

៣-**បុត្តទារេហិ** ចំរើនដោយកូន និង ប្រពន្ធ ។

៤-**ទាសកម្មករបោរិសេហិ** ចំរើនដោយទាសៈកម្មករ និង អ្នកបំរើ ។

៥-**ចតុប្បទេហិ** ចំរើនដោយសត្វជើង៤ ។

៦-**សទ្ធាយ** ចំរើនដោយសទ្ធា ។

៧-**សីលេន** ចំរើនដោយសីល ។

៨-**សុតេន** ចំរើនដោយសុតៈ (ការស្តាប់) ។

៩-**ចាគេន** ចំរើនដោយចាគៈ (ការលះបង់) ។

១០-**បញ្ញាយ** ចំរើនដោយបញ្ញា[១៩] ។

ព្រះពុទ្ធ ទ្រង់សរុបសេចក្តីថា –

បុគ្គលណាចំរើនដោយ ស្រែ ចំការ ទ្រព្យ ស្រូវ កូន ប្រពន្ធ ទាសៈ កម្មករ អ្នកបំរើ និង សត្វជើង៤ បុគ្គលនោះ ឈ្មោះថា មានជោគ[២០] មានយស ដែលពួកញាតិ មិត្រ និង សូម្បីតែព្រះរាជា បូជាហើយ ។ បុគ្គលណា ចំរើនដោយ សទ្ធា សីល សុតៈ ចាគៈ និង បញ្ញា បុគ្គលនោះ ឈ្មោះថា សប្បុរស អ្នក មានបញ្ញា រមែងចំរើនទាំងពីរប្រការក្នុងបច្ចុប្បន្ន នេះឯង។

គួរសង្កេត :

១-ក្នុងព្រះសូត្រនេះ សេចក្តីចំរើន ១០ ចែកជា ២ ផ្នែកគឺៈ

(១)-សេចក្តីចំរើន ៥ ខាងដើម ជាផ្នែកសម្ភារៈ ទ្រព្យ

---

(១៩) សុត្តន្តបិដក អង្គុត្តរនិកាយ ទសកនិបាត ៥០-៧៤-២៩៨

(២០)-គម្ពីរបរទេសថា ភគវា មានជោគ ប៉ុន្តែ គម្ពីរខ្មែរថា ភោគវា មានភោគៈ

សម្បត្តិ ចាត់ជាប្រយោជន៍ក្នុងបច្ចុប្បន្ន ។ (២)-សេចក្ដីចំរើន ៥ ខាងចុង ជាផ្នែកចិត្តគំនិត គុណធម៌ផ្សេងៗ ចាត់ជាប្រយោជន៍ក្នុងលោកខាងមុខ ។

២-បុគ្គលអ្នកចំរើនដោយសេចក្ដីចំរើន ១០ យ៉ាងនេះ ឈ្មោះថា កាន់យកនូវខ្លឹម កាន់យកនូវរបស់ដ៏ប្រសើរនៃរូបកាយ ។ រូបកាយ មិនមានខ្លឹមសារអ្វីទេ ជារបស់ពុកផុយរលួយជាធម្មតា ប៉ុន្តែ បើគេកសាងសេចក្ដីចំរើន ១០ យ៉ាងនេះបាន ឈ្មោះថា គេកាន់យកនូវខ្លឹម កាន់យកនូវវត្ថុដ៏ប្រសើរនៃរូបកាយ បានហើយ ។ មិនតែប៉ុណ្ណោះ បុគ្គលនោះ ព្រះពុទ្ធ ទ្រង់លើកតម្កើងជា អរិយសាវក ទៀតផង ។

៣-ក្នុងបទសរុប (និគមវចនៈ) ព្រះពុទ្ធទ្រង់ត្រាស់បន្ថែមថា បុគ្គលអ្នកចំរើន ៥ ខាងដើម ហៅថា ភគវា អ្នកមានជោគយសស្សី អ្នកមានយស ដែលពួកញាតិ មិត្រ និង ស្វាមីតែ ព្រះរាជាបូជាហើយ ។ ឯបុគ្គលអ្នកចំរើនដោយសេចក្ដីចំរើន ៥ ខាងចុង ហៅថា សប្បុរស អ្នកមានបញ្ញា រមែងចំរើនទាំងពីរប្រការក្នុងបច្ចុប្បន្ននេះឯង ។

៤-សេចក្ដីខាងលើនេះ បញ្ជាក់ថា បុគ្គលណាចំរើនដោយសេចក្ដីចំរើន ១០ យ៉ាងនេះ មានតម្លៃថ្លៃថ្លាណាស់ ។ ប៉ុន្តែ ខ្មែរយើង ច្រើនតែបដិបត្តិតែមួយកំណាត់ខាងដើម ឬ មួយកំណាត់

ខាងចុង គឺ បើគេអាចរកសេចក្តីចំរើនដោយទ្រព្យសម្បត្តិបាន គេធ្វើត្រឹមប៉ុណ្ណឹង គេមិនព្រមខំប្រឹងឈានទៅរកទាន សីលផងទេ ឬបើគេធ្វើទាន សីល ភាវនាវិញ គេឈប់ធ្វើការងារហើយ គេរត់ចោលប្រពន្ធ កូនហើយ ចោលប្រទេសជាតិហើយ ។ នេះជាគំនិតអាក្រក់ ដែលគេគប្បីប្រែធ្វើឲ្យគ្រប់ទាំង ១០ ប្រការវិញ ។

៥-ចំរើនដោយ កូន ប្រពន្ធ មិនមែនប្រែថា គេមានប្រពន្ធច្រើនទេ កុំច្រឡំ... គ្រាន់តែប្រាប់ថា គេមិននៅលីវទេ មានកូន ប្រពន្ធ ហើយ ។ ចំរើនដោយ ទាសៈ កម្មករ និង អ្នកបំរើ មិនមែនប្រែថា គេអ្នកជិះជាន់ មើលងាយមនុស្សទេ គ្រាន់តែប្រែថា គេមានការងារច្រើនប៉ុណ្ណោះ ។ល។

## **សមភាព** ក្នុងពុទ្ធសាសនា

ពុទ្ធសាសនា ឲ្យតម្លៃមនុស្សស្មើគ្នា

វណ្ណៈណា ឬ បុគ្គលណា ធ្វើអំពើទុច្ចរិតដោយកាយ វាចា ចិត្ត វណ្ណៈនោះ បុគ្គលនោះ លុះទំលាយកាយទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ស្មើគ្នា (ដូចគ្នា) ។ វណ្ណៈណា ឬបុគ្គលណា ធ្វើអំពើសុចរិតដោយកាយ វាចា ចិត្ត វណ្ណៈនោះ បុគ្គលនោះ លុះទំលាយកាយទៅ រមែងចូលទៅកាន់សុគតិ សួគ៌ ទេវលោក ស្មើគ្នា ។ វណ្ណៈណា បុគ្គលណា កាប់សម្លាប់គេ

លួចប្លន់ទ្រព្យសម្បត្តិគេ ប្រព្រឹត្តខុសក្នុងភរិយាគេ វណ្ណៈនោះ បុគ្គលនោះ ត្រូវដាក់ទោសស្មើគ្នា ។ វណ្ណៈណា បុគ្គលណា ចូលទៅបួសក្នុងពុទ្ធសាសនា វណ្ណៈនោះ បុគ្គលនោះ ត្រូវបាន ទទួលសេចក្តីគោរពស្មើគ្នា(២១) ។ល។

## បរាភវសូត្រ

ព្រះពុទ្ធ ទ្រង់ត្រាស់សម្តែងផ្លូវ(ហេតុ) ដែលនាំឲ្យវិនាស ដើម្បីឲ្យគេបានដឹង ងាយស្រួលក្នុងការគេចចេញពីផ្លូវដែលនាំឲ្យ វិនាសនោះ ។ ព្រះអង្គ ទ្រង់សម្តែង មានសេចក្តីដូចតទៅនេះ-

-អ្នកស្រឡាញ់ធម៌ ស្រឡាញ់ច្បាប់ ស្រឡាញ់សេចក្តីត្រឹមត្រូវ រមែងចំរើន ។ អ្នកស្អប់ធម៌... រមែងវិនាស ។

-អ្នកមិនស្រឡាញ់ សប្បុរស (មនុស្សល្អ) ស្រឡាញ់តែ អសប្បុរស (មនុស្សអាក្រក់) ទាំងចូលចិត្តស្តាប់ធម៌របស់ពួក អសប្បុរស រមែងវិនាស ។

-អ្នកដេកច្រើន អ្នកនិយាយច្រើន អ្នកមិនព្យាយាម អ្នក ខ្ជិលច្រអូស និង អ្នកខឹងច្រើន រមែងវិនាស ។

-អ្នកមានទ្រព្យច្រើន មិនចិញ្ចឹមមាតាបិតា ដែលចាស់ជរា

---

(២១)-សុត្តន្តបិដក មជ្ឈិមនិកាយ មធុរសូត្រ ២៤-២២៥-៣៣៥

មានវ័យកន្លងហើយ រមែងវិនាស ។

-អ្នកនិយាយកុហក បញ្ឆោត សមណៈក្តី ព្រាហ្មណ៍ក្តី ឬស្មូមជទៃទៀតក្តី រមែងវិនាស ។

-អ្នកមានទ្រព្យច្រើន មានប្រាក់ច្រើន មានអាហារភោជនល្អៗ ស៊ីឆ្ងាញ់តែម្នាក់ឯង ឬ តែគ្នាឯង រមែងវិនាស ។

-អ្នកក្រអឺត ក្រអោង អាងជាតិ អាងគោត្រត្រកូល អាងទ្រព្យសម្បត្តិ ហើយមើលងាយញាតិរបស់ខ្លួន រមែងវិនាស ។

-អ្នកលេងស្រី អ្នកលេងសុរា អ្នកលេងល្បែងភ្នាល់ បំផ្លាញទ្រព្យខ្លួនដែលបានមានហើយ រមែងវិនាស ។

-អ្នកមិនត្រេកអរនឹងប្រពន្ធរបស់ខ្លួន ហើយទៅត្រេកអរនឹងប្រពន្ធអ្នកដទៃ ឬ ស្រីពេស្យា រមែងវិនាស ។

-បុរសចាស់ជ្រុល យកស្រីក្រមុំធ្វើជាភរិយា ដេកមិនលក់ព្រោះប្រច័ណ្ឌវា រមែងវិនាស ។

-អ្នកដែលតាំងស្ត្រី ឬ បុរស អ្នកលេងខ្ជះខ្ជាយ ក្នុងតំណែងជាធំ(ឲ្យធ្វើធំ) រមែងវិនាស ។

-អ្នកកើតក្នុងត្រកូលស្តេច មានទ្រព្យសម្បត្តិ (និង សមត្ថភាព) តិច ប៉ុន្តែ មានចំណង់ច្រើន (ធំ) ប្រាថ្នានឹងសោយរាជ្យ រមែងវិនាស ។

-លោក អ្នក ជាបណ្ឌិត សម្បូរដោយទស្សនៈដ៏ប្រសើរ

ពិចារណាឃើញច្បាស់នូវសេចក្ដីវិនាសទាំងនុ៎ះក្នុងលោក គេចចេញពីនោះ មកសេពគប់នូវលោក ដែលមានសេចក្ដីសុខក្សេមក្សាន្តវិញ[២២] ។

## មង្គលសូត្រ

៙

### មង្គល

សេចក្ដីសុខ-ចំរើន សិរីសួស្ដី ជោគជ័យ

**ពហូ ទេវា មនុស្សា ច ...**

ទេវតា និង មនុស្សទាំងឡាយដ៏ច្រើន ប្រាថ្នានូវសួស្ដី បានគិតរកនូវមង្គលទាំងឡាយ សូមព្រះអង្គ ទ្រង់ត្រាស់សម្ដែងនូវមង្គលដ៏ឧត្ដម ។

**អសេវនា ច ពាលានំ ...**

ព្រះពុទ្ធ ទ្រង់ត្រាស់សម្ដែង ដូចតទៅនេះ –

-ការមិនសេពគប់ជនពាល ១ ការសេពគប់បណ្ឌិត ១ ការបូជាបុគ្គលដែលគួរបូជា ១ នេះ ជាមង្គលដ៏ឧត្ដម ។

-ការនៅក្នុងប្រទេសដ៏សមគួរ ១ ការបានធ្វើបុណ្យទុកក្នុងកាលមុន ១ ការតម្កល់ខ្លួនទុកប្រពៃ ១ នេះ ជាមង្គលដ៏ឧត្ដម ។

---

[២២]-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត ៥៥-១០-៣៦

-រៀនសូត្រច្រើន ១ ស្ទាត់ជំនាញក្នុងសិល្បៈ ១ មានរបៀបវិន័យ ១ ពាក្យសំដីល្អ ១ នេះ ជាមង្គលដ៏ឧត្ដម ។

-ការទំនុកបំរុងមាតាបិតា ១ ការសង្គ្រោះបុត្រ ១ ការសង្គ្រោះភរិយា ១ ការងារមិនច្របូកច្របល់ ១ នេះ ជាមង្គលដ៏ឧត្ដម ។

-ការធ្វើទាន ១ ការប្រព្រឹត្តធម៌ ១ ការសង្គ្រោះញាតិ ១ ការងារមិនមានទោស ១ នេះ ជាមង្គលដ៏ឧត្ដម ។

-ការមិនត្រេកអរ គឺការវៀរចាកបាប ១ សេចក្ដីសង្រួមចាកការផឹកទឹកស្រវឹង ១ សេចក្ដីមិនប្រមាទក្នុងធម៌ទាំងឡាយ ១ នេះ ជាមង្គលដ៏ឧត្ដម ។

-សេចក្ដីគោរព ១ សេចក្ដីឱនលំទោន ១ សេចក្ដីសន្ដោស ១ កតញ្ញូ ១ ការស្ដាប់ធម៌តាមកាល ១ នេះ ជាមង្គលដ៏ឧត្ដម ។

-សេចក្ដីអត់ធន់ ១ ភាពជាអ្នកប្រដៅងាយ ១ ការបានជួបសមណៈ ១ ធម្មសាកច្ឆាតាមកាល ១ នេះ ជាមង្គលដ៏ឧត្ដម ។

-សេចក្ដីព្យាយាមដុតបាប ១ ការប្រព្រឹត្តព្រហ្មចរិយធម៌ ១ ការបានឃើញនូវអរិយសច្ច ១ ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ១ នេះ ជាមង្គលដ៏ឧត្ដម ។

-ចិត្តនៃបុគ្គលណា ដែលលោកធម៌ពាល់ត្រូវហើយ មិនញាប់ញ័រ ១ មិនមានសេចក្ដីសោក ១ មានធូលី គឺរាគៈទៅប្រាសហើយ ១ ជាចិត្តក្សេមក្សាន្ត ១ នេះ ជាមង្គលដ៏ឧត្ដម ។

ទេវតា និង មនុស្សទាំងឡាយ ធ្វើនូវមង្គលទាំងឡាយ ប្រាកដដូច្នោះហើយ ជាអ្នកមិនចាលចាញ់ក្នុងទីទាំងពួង តែងដល់នូវសួស្តី ក្នុងទីទាំងពួង នោះជាមង្គលដ៏ឧត្តមរបស់ទេវតា និង មនុស្សទាំងឡាយនោះ[២៣] ៕

## រាជសង្គហវត្ថុ

វត្ថុសំរាប់សង្គ្រោះនៃព្រះរាជា ៤ យ៉ាង

១-**សស្សមេធះ** ឆ្លាតក្នុងការចែក ពូជស្រូវ ពូជដំណាំផ្សេងៗ ជម្រុញឲ្យកសិកម្មរីកចំរើនឡើង ។

២-**បុរិសមេធះ** ឆ្លាតក្នុងការអប់រំ ទំនុកបំរុង ទាហាន... និងអ្នករាជការ ឲ្យមានគុណសម្បត្តិ សមត្ថភាព និង មានប្រាក់ខែគ្រប់គ្រាន់ ។

៣-**សម្មាបាសះ** ចងចិត្តប្រជាជន ដោយការចែកធនធានដល់អ្នកក្រ ដោយការឲ្យប្រាក់កម្ចី ដល់អ្នកជំនួញ អ្នកបង្កបង្កើនផលផ្សេងៗ ជួយឲ្យប្រជាជនមានជីវភាព ប្រហាក់ប្រហែលគ្នា ។

៤-**វាជបេយ្យំ** សំដីពីរោះ មានហេតុផល ស្តាប់ងាយយល់ ចេះបង្រួបបង្រួម ឲ្យមានសាមគ្គីភាព និង ចេះលើកទឹកចិត្ត

---

[២៣]-សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត ៥៤-២៤-៨៥

ឲ្យមានកម្លាំង ខំប្រឹងប្រែងធ្វើការងារ...[២៤] ។

## មហាយញ្ញ ៥

១-**អស្សមេធះ** សម្លាប់សេះ បូជាយញ្ញ

២-**បុរិសមេធះ** សម្លាប់មនុស្ស បូជាយញ្ញ

៣-**សម្មាបាសះ** បោះឈើបូលឲ្យចូលក្នុងរង្វង់អន្ទាក់ (កង) ធ្លាក់ចុះមកត្រង់កន្លែងណា យកកន្លែងនោះជាទីបូជា

៤-**វាជបេយ្យ** ពិធីស៊ីផឹកឲ្យមានកម្លាំង ឬ ក្នុងពេលមានជ័យជំនះ

៥-**និរគ្គឡ ឬ សព្វមេធះ** មិនមានគន្លឹះ (មិនមានកំណត់) សត្វអ្វីក៏យកមកបូជាបាន [២៥] ។

ដើម្បីឲ្យបានផលប្រយោជន៍ដល់ពួកខ្លួន ពួកព្រាហ្មណ៍បានយក រាជសង្គហវត្ថុ ៤ នោះ មកកែប្រែ បកស្រាយផ្សេង ពីន័យដើម គឺទៅជា មហាយញ្ញ ៥ យ៉ាងខាងលើនេះ ។ ឯពាក្យថា និរគ្គឡ ន័យដើមថា មិនមានគន្លឹះ ជាផលនៃរាជសង្គហវត្ថុ គឺស្រុកសុខសប្បាយ គ្មានចោរខ្មួយទេ មិនបាច់មានគន្លឹះចាក់សោបិទទ្វារទេ ។

---

[២៤]-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២-៤០-១០១

[២៥]-សុត្តន្តបិដក សំយុត្តនិកាយ កោសលសំយុត្ត ២៩-៣៥៣-២០៧

ធម៌របស់ព្រះពុទ្ធ ដែលជាប្រយោជន៍ដល់សង្គម ក្នុងជីវិតបច្ចុប្បន្ននេះ នៅមានទៀត ច្រើនណាស់ ប៉ុន្តែ ខ្ញុំ សុំបញ្ចប់ត្រឹមប៉ុណ្ណឹងចុះ ។

## សំណួរ ចម្លើយ

១❋១

ស- ព្រះពុទ្ធ សម្តែងធម៌សំរាប់សង្គមមនុស្សច្រើនណាស់ ប៉ុន្តែ សម័យសព្វថ្ងៃ មានព្រះសង្ឃ និង អាចារ្យខ្លះ គេមិននិយាយទេ គេថាមិនមែនជាការងាររបស់គេ តើវាយ៉ាងម៉េចទៅ ?

ច- រឿងរបស់គេ ខ្ញុំមិនដឹងដែរ ប៉ុន្តែ ចំពោះខ្ញុំ ខ្ញុំគិតថា យើងកើត យើងរស់ អាស្រ័យផែនដី អាស្រ័យប្រជាជន យើងត្រូវគិត សងគុណផែនដី សងគុណប្រជាជនខ្លះ បើយើងគិតយកសុខផ្ទាល់ខ្លួន ធ្វើមិនដឹងមិនឮយ៉ាងហ្នឹង ដូចជាអកតញ្ញូពេក ។ ព្រះបរមគ្រូរបស់យើង មិនប្រដៅដូចនេះទេ មិនធ្វើដូចនេះទេបានជាមានគម្ពីរ មានពាក្យប្រៀនប្រដៅទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ពេលដែលពួកព្រះញាតិ ឈ្លោះគ្នា ព្រះអង្គជួយសម្រុះសម្រួល... ពេលដែលប្រទេសជិតខាងចូលមកបៀតបៀន ព្រះអង្គ រកឧបាយជួយការពារ... ។ល។

ស- ព្រះសង្ឃ គួរមានសិទ្ធិបោះឆ្នោតរើសតំណាងរាស្ត្រ បានឬទេ ?

ច- យោបល់ អាងសិទ្ធិ អាងប្រយោជន៍ ចេះតែមាន ប៉ុន្តែសំរាប់ខ្ញុំ ខ្ញុំយល់ថា ព្រះសង្ឃមិនគួរបោះឆ្នោតទេ ព្រោះ –

១-បើយើងបោះឆ្នោត ប្រែថា យើងមានគណៈបក្ស បើ មានគណៈបក្ស មុខជាមានទំនាស់នឹងឧបាសក ឧបាសិកា ដែល មានបក្សផ្សេងគ្នា ពិបាកធ្វើបុណ្យ ដូច្នេះ កុំបោះឆ្នោតល្អជាង ។

២-ថ្ងៃហ្នឹង មានសិទ្ធិបោះឆ្នោត ថ្ងៃស្អែក មានសិទ្ធិអ្វីៗ ទៀត ឃ្លាតទៅអស់ភាពជាព្រះសង្ឃហើយ ។ ឮថា នៅប្រទេស សិរីលង្កា ព្រះសង្ឃខ្លះមានប្រពន្ធ កូន ដូចគ្រហស្ថដែរ សព្វថ្ងៃ រដ្ឋាភិបាល កំពុងតែបង្ក្រាប កំពុងតែដោះស្រាយ ។ ការពារ ប្រសើរជាង ព្យាបាល ។ រឿងបោះឆ្នោត ទុកជូនប្រជាជន គ្នា ច្រើន ដោះស្រាយឲ្យបានយុត្តិធម៌ត្រឹមត្រូវផងចុះ យើងព្រះសង្ឃ គ្នាបន្តិចបន្តួច គួរលើកលែង តម្កល់ទុកជាទីគោរពសក្ការៈ ទាំង អស់គ្នា ល្អជាង ។

ស- ពីដើមមក មិនដែលឃើញព្រះសង្ឃសំពះគ្រហស្ថ ប៉ុន្តែសព្វថ្ងៃនេះ ឃើញមានព្រះសង្ឃ សំពះគ្រហស្ថ តើរឿងហ្នឹង ខុស ឬ ត្រូវ ? ព្រះពុទ្ធ សម្តែងទុកយ៉ាងម៉េចដែរ ?

ច-ខ្ញុំ មិនដែលឃើញ មិនដែលឮ ព្រះសង្ឃសំពះគ្រហស្ថ ដែរ ព្រះសង្ឃខ្មែរពីដើម ព្រះសង្ឃលង្កា ភូមា ថៃ ឡាវ មិនដែលសំពះគ្រហស្ថទេ ទើបតែព្រះសង្ឃខ្មែរសព្វថ្ងៃ គេនាំគ្នាសំពះគ្រហស្ថ មិនដឹងជាគេចេះមកពីណា ? នេះ ពិតជាមិនមែនចេះមកពីរៀន គឺដេក... ដេកទៅភ្ញាក់ឡើងចេះតែម្តង ។ សួរថា ខុស ឬ ត្រូវ ? បើពួកអាយ៉ៃ គេឆ្លើយថាត្រូវ ត្រូវចំកន្ទែងខុស ។ រឿងនេះ មានសម្តែងទុកក្នុងគម្ពីរព្រះត្រៃបិដក ដូចតទៅនេះ-

ព្រះឧបាលិ ក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គ ដ៏ចំរើន បុគ្គលដែលភិក្ខុមិនគួរសំពះ មានប៉ុន្មានពួក ? ព្រះពុទ្ធ ទ្រង់ត្រាស់ថា ម្នាលឧបាលិ បុគ្គលដែលភិក្ខុមិនគួរសំពះ មាន៥ពួកគឺ:

១-ភិក្ខុដែលបួសក្រោយ ។

២-អនុបសម្បន្ន (សាមណេរ ឬ បុរស) ។

៣-ភិក្ខុមានសំវាសផ្សេងគ្នា ជាអធម្មវាទី សូម្បីចាស់វស្សាជាងក៏ដោយ ។

៤-មាតុគ្រាម (ស្ត្រី) ។

៥-បណ្ឌក (ខ្ទើយ)[២៦] ៕

។ល។

---

[២៦]-វិន័យបិដក បរិវារ ១៣-៣០៨-៣៥៧

ស- ព្រះពុទ្ធសាសនា (ព្រះសង្ឃ) សព្វថ្ងៃនេះ គួរជួយប្រទេសជាតិ ជួយប្រជាជន យ៉ាងម៉េចដែរ ?

ច-រឿងដែលត្រូវជួយ មានច្រើនណាស់ ព្រះសង្ឃយើងបានជួយខ្លះហើយ ប៉ុន្តែជួយបានតិចៗ រៀងៗខ្លួន ។ តាមមតិខ្ញុំត្រូវជួយឲ្យមែនទែន គគ្រឹកគគ្រេង ក្នុងនាមគណៈសង្ឃ ក្នុងនាមក្រសួងធម្មការ យើងត្រូវទុកជាទិសដៅមួយ ក្នុងបណ្តាទិសដៅសំខាន់ៗរបស់សាសនា ។ យើងមិនមែនគ្រាន់តែ មិនប្រឆាំងរដ្ឋាភិបាលប៉ុណ្ណោះទេ យើងជួយរដ្ឋាភិបាល យើងមិនប្រឆាំង មិនទំនាស់នឹងបុគ្គលណាៗទាំងអស់ ។ យើងនាំគ្នាខំប្រឹងជួយដាស់ប្រជាជនឲ្យភ្ញាក់រលឹកឃើញទោសនៃអបាយមុខ... យ៉ាងគគ្រឹក - គគ្រេង គ្រប់ទិសទី យើងជួយលើកទឹកចិត្តប្រជាជនឲ្យភ្ញាក់រលឹកខំកសាងខ្លួន កសាងជីវភាពឲ្យបានគ្រាន់បើជាបណ្តើរៗឡើង តាមមធ្យោបាយដែលពួកយើងមាន... ។ គំនិតខ្ញុំកើត កំណើតខ្ញុំមានអ្វីៗ គំនិតកើតមុន ។ ជួយ ប៉ុណ្ណោះ ជាដើម ៕

៚ល៚

ស- ទីកន្លែងវត្ត គេអាចធ្វើនយោបាយ បាន ឬ ទេ ?

ច- វត្តមិនមែនជាកន្លែងធ្វើនយោបាយទេ វត្តជាកន្លែងរៀនធម៌ បដិបត្តិធម៌ ជាកន្លែងស្ងប់ស្ងាត់ សំរាប់អប់រំចិត្ត ។ ប៉ុន្តែវត្តជាជម្រករបស់ប្រជាជន ដូចមានពាក្យថា ព្រះសង្ឃ កំពង់សត្វ ។

តាំងពីណោពីណាមក សម័យសៀម សម័យយួន សម័យបារាំង ខ្មែររត់ទៅជ្រក ទៅទីពឹងវត្ត... ឯវត្ត ក៏មិនដែលបោះបង់ចោល ប្រជាជនដែរ ។ រឿងនេះ ខ្មែរទាំងអស់គ្នា ត្រូវតែដឹង ត្រូវតែយល់។ កុំឈ្លោះគ្នា ត្រូវគិតពិចារណា ធ្វើយ៉ាងម៉េច បានសុខ បាន ចំរើន ទាំងអស់គ្នា ។ កុំធ្វើអ្វីតាមចិត្តយើងម្នាក់ៗ ឬ មួយក្រុមៗ អ្នកនិយាយ កុំនិយាយតាមចង់ទាំងអស់ ចង់ជេរ... ជេរ ដូច្នេះ មិនសមគួរទេ អ្នកគិតនាំគ្នាមកប្រឆាំង ប្រឈមមុខគ្នា ត្រូវតែ គិត តើគេធ្វើដើម្បីនរណា ? បើដើម្បីខ្មែរ គួរតែជួយសម្រប សម្រួលគ្នាខ្លះផងដែរ ឯអ្នកហាមឃាត់ មិនឲ្យគេនិយាយក្នុងវត្ត ឲ្យទៅរកកន្លែងក្រៅវត្ត ល្អហើយ ប៉ុន្តែ មិនមែនជាការងាយទេ ។ ដូចនេះ ត្រូវប្រើបញ្ញាឲ្យច្រើន ត្រូវគិតសម្របសម្រួលគ្នា សាមគ្គី គ្នាឲ្យបាន ព្រោះការបាក់បែកគ្នា មិនមែនជាប្រយោជន៍របស់ ខ្មែរទេ ។

ស-អ្នកខ្លះថា បើមាននិយាយ នយោបាយ ក្នុងវត្ត គេ មិនចង់ចូលវត្តទេ វត្តត្រូវតែស្ងប់ស្ងាត់ ។

ឆ-តាមពិត ការនិយាយជាប់ទាក់ទង នយោបាយ ក្នុងវត្ត បើមានក៏បន្តិចបន្តួចប៉ុណ្ណោះ នៅមានពេលទំនេរភាគច្រើនទៀត ដែលយើងអាចរៀនធម៌ បដិបត្តិធម៌បាន ។ ការទាមទារ ស្ងប់ ស្ងាត់១០០% មិនជាការងាយទេ ។ តាមខ្ញុំដឹង សាសនាឯទៀត

មានរឿងឈ្លោះគ្នា ច្បាំងគ្នា រវាងសាសនាគ្នាឯង ក៏មាន ច្បាំងនឹងសាសនាដទៃ ក៏មាន ។ ពុទ្ធសាសនាយើង ធ្លាប់រងគ្រោះដោយសារសាសនាដទៃ ច្រើនដង ច្រើនលើកណាស់ ។ ប៉ុន្តែពុទ្ធសាសនា មិនដែលច្បាំងគ្នាឯង ឬ ច្បាំងជាមួយសាសនាដទៃឡើយ ។ សាសនាយើង មានសេចក្តីល្អ ច្រើនណាស់ មិនចាញ់សាសនាដទៃទេ ។ មិនគួររត់ចោលវត្ត ដោយសារតែហេតុបន្តិចបន្តួច ប៉ុណ្ណោះទេ ត្រូវតែនាំគ្នាចូលវត្ត មករៀនសូត្រ មកបដិបត្តិ មកជួយគ្នាចាត់ចែងកែលំអ ឲ្យកាន់តែប្រសើរឡើង ៕

## សង្ឃកំពង់សត្វ

៙*៙

សង្ឃកំពង់សត្វ ដែលមានវិបត្តិ មានទុក្ខមានភ័យ
ចូលមកពឹងពាក់ ពំនាក់អាស្រ័យ បំបាត់ទុក្ខភ័យ
មួយដងមួយកាល ។

ព្រះសង្ឃអ្នកធម៌ ព្រះទ័យស្មោះសរ តែងជួយឈឺឆ្អាល
ទុក្ខភ័យដែលធ្ងន់ គិតគន់ឲ្យស្រាល ឬ ថ្នមបណ្តាល
ឲ្យបាត់តែម្តង ។

ថែមទាំងប្រាប់ផ្លូវ ដ៏ល្អត្រឹមត្រូវ ដើរទៅឥតហ្មង
មានតែក្តីសុខ ឥតទុក្ខភ័យផង ប្រសើរកន្លង
គឺ អរិយមគ្គ ៕

## ព្រះសង្ឃ និង គ្រហស្ថ គប្បីអាស្រ័យគ្នានឹងគ្នា

ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ និង គហបតីទាំងឡាយ ទំនុកបំរុងភិក្ខុសង្ឃ ដោយបច្ច័យបួន គឺ ចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជៈ ឈ្មោះថា ជាអ្នកមានឧបការច្រើន។ សូម្បីភិក្ខុទាំងឡាយ សំដែងធម៌ លំអបទដើម លំអបទកណ្តាល លំអបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និង ព្យញ្ជនៈ បរិសុទ្ធ បរិបូណ៌ សព្វគ្រប់ ដល់គ្រហស្ថទាំងឡាយ ក៏ឈ្មោះថា ជាអ្នកមានឧបការៈច្រើន ។ ម្នាលភិក្ខុទាំងឡាយ គ្រហស្ថ និង បព្វជិត អាស្រ័យគ្នានឹងគ្នា ដោយអាមិសទាន និង ធម្មទាន ប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីឆ្លងនូវអន្លង់ឱឃៈ ដល់ទីបំផុតនៃទុក្ខ ដោយបការៈយ៉ាងនេះ [២៧] ៕

## ស៊ុំ ក៏រស់ខម្ពស់ផែនដី

---

[២៧]-សុត្តន្តបិដក ឥតិវុត្តកៈ ពហុការសូត្រ ៥៣-១០៩-១៤៣

# លោកអ្នកសប្បុរស ដែលជួយឧបត្ថម្ភការបោះពុម្ព

| | |
|---|---|
| ១-អាចារ្យ មិន ធូ ឧបាសិកា តាំង វួចហៅ | ២០ € |
| ២-ឧបាសិកា នៅ ទាវខេង និង បុត្រធីតា | ២០ € |
| ៣-ឧបាសិកា ប៊ុន ហ៊ុលឃុត | ២០ € |
| ៤-ឧបាសិកា អ៊ឹង អាង | ២០ € |
| ៥-លោក ណុប ពុទ្ធីរ៍ និង គ្រួសារ | ២០ € |
| ៦-លោក ង៉ី ហុក និង ភរិយា | ២០ € |
| ៧-លោក ខៀវ ឡេង និង ភរិយា | ២០ € |
| ៨-ឧបាសិកា ណែម លិមអ៊ាន | ២០ € |
| ៩-ឧបាសិកា ណែម លិមអ៊ុន | ២០ € |
| ១០-ឧបាសិកា អៀង ហុង | ១៥ € |
| ១១-ឧបាសិកា ស៊ីសុវត្ថិ ក្រិត្យនារី | ២០ € |
| ១២-ឧបាសិកា គុល ទូច | ៥០ € |
| ១៣-ឧបាសិកា ឈា ឡេងហាក់ | ២០ € |
| ១៤-ឧបាសិកា នេត្រ គួន | ២០ € |
| ១៥-ឧបាសិកា កឹម សួផន | ២០ € |
| ១៦-ឧបាសិកា អាត អេង និង បុត្រ | ១៥ € |
| ១៧-ឧបាសិកា យី អេងឡាំ | ២០ € |
| ១៨-ឧបាសិកា ពៅ គាតស្ងួរី | ២០ € |

១៩-ឧបាសិកា យក់ លាន ២០ €

២០-ឧបាសក ណៃ ហួរ ២០ €

២១-ឧបាសក តាន់ ណាំ ឧបាសិកា លិម ឆេងអ៊ី ៤០ €

២២-ឧបាសិកា ឡាយ រ៉ុ ២០ €

២៣-អ្នកស្រី យិន មុំ ២០ €

២៤-អ្នកស្រី ផាត ឡាង ២០ €

២៥-លោក និង អ្នកស្រី ផាយ វ៉ាន ២០ €

២៦-លោកស្រី ប៊ុន ហ៊ុនគី ២០ €

២៧-ឧបាសិកា មួន សាវ៉ាត់ និង កូនចៅ ២០ €

២៨-ឧបាសិកា តេង សម្បត្តិ ២០ €

២៩-ឧបាសិកា ទី វណ្ណហង្ស ១៥ €

៣០-អ្នកស្រី សេហ្គា ឡី និងកូនចៅ ២០ €

៣១-ឧបាសិកា ចាន់ ហឿន និង កូនចៅ ២០ €

៣២-អ្នកស្រី ឡាវ គីមហ្គេច និង កូនចៅ ២០ €

៣៣-ឧបាសិកា ទា គីមលី ២០ €

៣៤-ឧបាសិកា ទា គីមលន់ ២០ €

៣៥-លោក លីម ហ៊ុយគៀង អ្នកស្រី ម៉ៅ ទៀង ៥០ €

៣៦-លោក សួង ណារឿន និង ភរិយា ២០ €

៣៧-លោក ជួន ទីម អ្នកស្រី ទិត ពៅ ២០ €

៣៨-លោក អ៊ិន សារ៉េន និង ភរិយា ២០ €

៣៩-អ្នកស្រី អ៊ូច សុខា ចន្ថា ២០ €

៤០-ឧបាសិកា ឃិន ហុកទីវ ១៥ €

៤១-ឧបាសិកា សុត សុផានី ១៥ €

៤២-ឧបាសិកា សៀប គីមហ៊ាង ១៥ €

៤៣-ឧបាសិកា ជូ ម៉ាក់ ១៥ €

៤៤-ឧបាសិកា តាំង អ៊ឹម ១៥ €

៤៥-ឧបាសិកា អ៊ុំ យន ១៥ €

៤៦-លោក និង អ្នកស្រី ស៊ាម ហ៊ុច ១៥ €

៤៧-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត ១៥ €

៤៨-ឧបាសិកា ឡៅ សាយឃីម ១៥ €

៤៩-ឧបាសិកា ជីប ហុង យ៉េន ១៥ €

៥០-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៥១-អ្នកស្រី ឡៅ ហុង ស៊ីម និង បុត្រធីតា ១៥ €

៥២-ផុង សួនីថា និង ស៊ុន ណារេត ១៥ €

៥៣-ឧបាសិកា ញ៉ឹក សាយ៉ាន់ ១៥ €

៥៤-អ្នកស្រី គីម មួយ ២០ €

៥៥-អ្នកស្រី ត្រាន់ ជូ ២០ €

៥៦-លោក ប៊ុន សម្បត្តិ ២០ €

៥៧-លោក ទេព ប៊ុនថាក់ណា និង អ្នកស្រី ប៉ុក ម៉ូរ៉ានី ២០ €

៥៨-លោក និង អ្នកស្រី យ៉ា ណោត ២០ €

៥៩-លោក និង អ្នកស្រី សរ ស៊ុន ហៀក ២០ €

៦០-លោក និង អ្នកស្រី យី សេង ឡុង ២០ €

៦១-លោក សុខ ខេមរ័តន៍ ២០ €

៦២-ឧបាសក ជា ជួន ១០ €

៦៣-ឧបាសិកា ថន សាម៉ុឌី និង ស្វាមី ២០ €

៦៤-ឧបាសិកា អ៊ុង លីម ស៊ីវប៊ួយ ១០ €

៦៥-លោក ធុច រត្តនា ២០ €

៦៦-កុល សូរ៉ាវី ២០ €

៦៧-អ្នកស្រី ភូ សុភាព ២០ €

៦៨-ឧបាសិកា អ៊ុច ជួង ២០ €

៦៩-ឧបាសិកា ផាវ ស៊ីវហួង និង កូនចៅ ២០ €

៧០-Mr et Mme Tan Nicolas ៣០ €

៧១-Mme VO-KIM SIVVAN ៣០ €

៧២-ឧបាសក តាន់ ស៊ុយ ឧបាសិកា សៅ ស៊ុយិន ៥០ €

៧៣-ឧបាសិកា មុត ឡឹង ឡុក យីវ និង កូនចៅ ៥០ €

៧៤-ឧបាសិកា យីវ លាង ៤៥ $

៧៥-លោក និង លោកស្រី តេង សេងហៃ ៣០ €

៧៦-ឧបាសិកា សួស សុភាព ២០ €

៧៧-លោក ស៊ីម៉ុង និង ភរិយា កូន ១០ €

៧៨-Mr. IN DANA ១០ €

៧៩-Mr. IN DANO ១០ €

៨០-Mr. IN DANEA ១០ €

៨១-Mme IN MADA ១០ €

៨២-ឧបាសិកា អ៊ុក សារ៉េត ២០ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះ លោកអ្នកដ៏មានគុណទាំងឡាយ មានមាតាបិតា ជីដូនជីតា គ្រូឧបជ្ឈាយាចារ្យ និង ញាតិកាសាលោហិត មិត្រសំឡាញ់ជាដើម ។ សូមលោក អ្នក ដ៏មានគុណទាំងឡាយជាដើមនោះ អនុមោទនាចំពោះបុណ្យកុសលនេះ ហើយទទួលយកនូវឥដ្ឋមនុញ្ញផល ជាទីគាប់ចិត្តកុំបីអាក់ខានឡើយ ។ល។

**វត្តពោធិវង្ស ប្រទេសបារាំង**

101, Boulevard de la République
77420 Champs sur Marne
Tél : 01 60 06 44 98

# រស់ទម្ងន់ផែនដី

១៧៨

រស់នៅទម្ងន់ ធ្ងន់តែផែនដី
មិនបានការអ្វី ផល់ផែនដីសោះ
ខ្លួនឯងបានសព្វ រៀបរាប់មិនអស់
លុះផែនដីខ្សោះ នាំគ្នារត់ចេញ ។
ស្រុកនេះមានទុក្ខ ក្តៅក្រហាយណាស់
យើងប្រែក្រឡាស់ ទៅស្ថានសួគ៌វិញ
ទីនោះសុខសាន្ត ពិតបានចំណេញ
ពួកយើង ចេញ ចេញ ! កុំស្តាយវាអី ។
អួតអាងបានធម៌ ល្អឥតប្រយោជន៍
អន់ជាងពួកខ្មោច គោ និង ក្របី
វារស់ វាស្លាប់ ចំរើនផែនដី
ធម៌អន្យត្ថិយ៍ ចង្រៃរោរព ។
បងប្អូនរួមជាតិ មើលឲ្យជាក់ច្បាស់
មុននឹងសំពះ មុននឹងគោរព
បើជួយសាងសុខ ចំរើនសព្វគ្រប់
គោរព គោរព ! លើកតម្កើងចុះ ។ល។